# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែធ្នូ លេខ ១២

ព. ស. ២៤៩៤ — គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* | បញ្ជីរឿង | *ទំព័រ*


| | | |
|---|---|---|
| ពុទ្ធសាសនានឹងគ្រិស្តសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតមីគ្វត់) (ចប់)... | លោកវ៉ាយ-ប៊ុក ......... | ៨៨៦ |
| ពន្ធអាស៊ីទ្វីប (តមក)........... | លោកវ៉ាយ-ប៊ុក ......... | ៨៩៥ |
| លោកបាលធម៌.............. | ព្រះអរិយកស្សប គុង-ឈួន .. | ៩០២ |
| កវិធម្មភាសិត................. | ព្រះមហា ឱម-តាំគ្រី ...... | ៩០៧ |


*ផ្នែកអក្សរសាស្ត្រ*


| | | |
|---|---|---|
| សុភាសិតប្រឌិតរឿង ............. | ព្រះមហា អ៊ុម-សុខ ...... | ៩១១ |
| រឿងអាយោនទាហានចាស់ ......... | សាស្ត្រាចារ្យ ផេង-ជ្រីវ ..... | ៩១៤ |
| ការបណ្ដុះនិស្ស័យ (តមក)........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... | ៩២៥ |
| រឿងសាមកុក (តមក)........... | ឧកញ៉ា ឡូ-កន ......... | ៩៣០ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).. | ឧកញ៉ា ឈឹម-ក្រសេម..... | ៩៣៨ |
| រឿងអារក្សថ្លៃងរឿងម្ដេប្រាំ (តមក).... | លោកសាង-សារ៉ាត....... | ៩៤២ |


*កំណត់ទីនប្រវត្តិការណ៍*


| | | |
|---|---|---|
| ពិធីប្រឡងធម្មវិន័យ វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប ............. | ព្រះមហា កែ-អឿន ...... | ៩៥៣ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៤៥ រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE


| | | Pages |
|---|---|---|
| Bouddhisme et Christianisme (Conférence du Doct. Migot) (suite et fin) | *M. RAY-BUC* | 886 |
| La Lumière de l'Asie (suite) | *M. RAY-BUC* | 895 |
| Lokapâladharma | *Vén. Tong Chhuon* | 902 |
| Kavidhammabhasita | *M. Om Nakry* | 907 |


### PARTIE LITTERAIRE


| | | |
|---|---|---|
| Subhasita-prâdit-roeung | *Vén. Oum Sok* | 911 |
| Histoire d'Yon le soldat (conte roumain) | *M. Pheng Chrieu* | 914 |
| Education morale (suite) | *Vén. PEUNG-PAM* | 925 |
| Histoire de SAMBOK (suite) | *Oknha NOU-KAN* | 930 |
| Histoire du Royaume du Cambodge (suite) | *Oknha CHHIM-KRASEM* | 938 |
| Les vingt-cinq récits du mauvais Génie (suite) | *M. SANG-SAVATH* | 942 |


### NOTES ET CHRONIQUES


| | | |
|---|---|---|
| Concours de Sortie de l'Ecole Dhamma-Vinaya à Vat Krapoum-Rat (Siamréap) | *Vén. Ker Oeun* | 953 |


Prix d'abonnement annuel comprenant 12 numéros: 145$00

# សេចក្ដីជូនដំណឹង

## អំពីទស្សនាវដ្ដី កម្ពុជសុរិយា ឆ្នាំ ១៩៥២

## ផ្សាយចេញ

## អំពីពុទ្ធសាសនបណ្ឌិត្យ

បងប្អូនរួមជាតិទាំងឡាយ ! សៀវភៅទស្សនាវដ្ដី កម្ពុជសុរិយា ជាដូចជាព្រះអាទិត្យខ្មែរមួយ សម្រាប់បញ្ចេញផ្លែ គឺអក្សរសាស្ត្រខ្មែរនិងពុទ្ធសាសនា ដែលពុទ្ធសាសនបណ្ឌិត្យធ្លាប់បានចេញផ្សាយរាល់ខែរៀងរាល់ឆ្នាំ ជាយូរឆ្នាំមកហើយនោះ, ក្នុងឆ្នាំ ១៩៥២ នេះ នឹងចេញផ្សាយតទៅទៀត ។

សៀវភៅនេះ ជាសៀវភៅអក្សរខ្មែរ ដែលនឹងមានជីវិតចំរើនរីកធំច្រើនឡើងតទៅក្នុងអនាគត ដោយសារតែខ្មែរយើងប៉ិនមើលបានអានច្រើនគ្នាជាងសព្វថ្ងៃនេះ ។ ហេតុដែលនាំឲ្យខ្មែរចូលចិត្តមើលអាននូវសៀវភៅអក្សរខ្មែរ ច្រើនគ្នានោះ. មកពីខ្មែរមានសន្ដានជាខ្មែរស្នេហាជាតិ ។ ព្រោះថាធម្មតា ជនណាដែលស្រឡាញ់ជាតិគេពិត ៗ គេតែងស្រឡាញ់អក្សរសាស្ត្រនិងភាសារបស់គេ ។ ខ្មែរយើង បើស្រឡាញ់ជាតិយើង គង់លើកតំកើងអក្សរសាស្ត្រនិងភាសាយើងដោយកិច្ចរៀន ខំអាន ខំសរសេរ ខំនិយាយ ព្រមទាំងប្រុងប្រើអក្សរខ្មែរនិង

ភាសាខ្មែរជាផ្លូវការ ដែលទាក់ទងរវាងខ្មែរនឹងខ្មែរ មិនមែន ដើកផ្សំផ្សិល រម្ងួលផ្សំគ្រប់ ដូចសព្វថ្ងៃនេះទេ ។

ពុទ្ធសាសនបណ្ឌិត្យសង្ឃឹមទុកចិត្ត ចំពោះខ្មែរស្នេហាជាតិសម័យបច្ចុប្បន្ននេះ ថានឹងមិនបណ្ដោយឲ្យអក្សរសាស្ត្រជាតិខ្លួនរលត់រលាយទៅទេ ទើបសូមជូនដំណឹងអំពីរឿងការ ផ្នែកសាសនានឹងផ្នែកអក្សរសាស្ត្រ ដ៏មានសារប្រយោជន៍សំខាន់ នឹង ពីរោះពីសាដល់អ្នកអាន ដែលបានគ្រោងទុកបម្រុងនឹងចុះផ្សាយ ក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ឆ្នាំ ១៩៥២ ដូចមានកយមាតិកាតទៅនេះ :—

## ផ្នែកសាសនា

១ — ដំណឹងផ្សេងៗ ក្នុងព្រះពុទ្ធសាសនា

២ - ធម្មទេសនា ដែលមានអត្ថរសប្លែកៗ

៣ — សីលធម៌របស់ព្រះពុទ្ធសាសនា

៤ — រឿងព្រះសូត្រនឹងបរមត្ថខ្លះ ដែលជាផ្លូវប្រតិបត្តិ ។

## ផ្នែកអក្សរសាស្ត្រ

១ — អក្សរសាស្ត្រខ្មែរ (គោលចារិកខាងផ្នែកអក្សរសាស្ត្រខ្មែរ ព្រមទាំងពាក្យកាព្យឃ្លោងចាស់ៗ ប្ដុំនេប)

២ — ព្រះរាជពង្សាវតារប្រទេសកម្ពុជា តៗគ្នាតាមលំដាប់

៣ — ឯកសារ (រឿងការសំខាន់ៗ ដូចសិលាចារិកជាដើម)

៤ – រឿងសាមកុក គ ៗ គ្នាតាមលំដាប់ ត្រាតែចប់

៥ – វប្បធម៌ (ពាក្យបារាំងប្រែជាខ្មែររបស់គណៈកម្មការវប្បធម៌)

៦ – សុភាសិតផ្សេង ៗ របស់ជាតិយើងនិងនានាជាតិ

៧ – រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់នានាជាតិ

៨ – រឿងទំនៀមទំលាប់ខ្មែរ របស់គណៈកម្មការទំនៀមទំលាប់ ។ល។

ហេតុនេះ សូមអស់លោក អ្នកដែលមានបំណងជាវទស្សនាវដ្ដី កម្ពុជសុរិយា ប្រចាំឆ្នាំ ១៩៥២ សូមផ្ញើឈ្មោះចុះនាមទីលំនៅ និងប្រាក់ ចំនួន ១៨៣ រៀលជាថ្លៃជាវ ១ ឆ្នាំ ១២ សៀវភៅទៅ អគ្គលេខាធិការ នៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ M. le Secretaire général de l'Institut Bouddhique Pbom-Penh ក្នុងពេលឆាប់ ៗ ដើម្បី ប្រមូលនាមអ្នកជាវទៅគណនាឲ្យដឹងចំនួន ហើយនឹងចាត់ការបោះពុម្ព តាមចំនួននោះ ។

ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ១៩៥១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

# ពុទ្ធសាសនា និង គ្រិស្តសាសនា

## សន្និសីទលោកវេជ្ជបណ្ឌិត មីគូត៍

លោក ក៉យ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្ដី «ហ្វ្រង្ស-អាស៊ី» ខែមិថុនា ឆ្នាំ ១៩៥០

(តចប់)

ចំណែកខាងប្រទេសទាំងប៉ុន្មាន ដែលកាន់ព្រះពុទ្ធសាសនាសឹងមានសភាពផ្សេងខុសគ្នាពីនានាប្រទេសខាងលើនេះ ។ ព្រោះព្រះពុទ្ធសាសនា ប្រាជ្ញាស្ថិតនៅលើវត្ថុធាតុ លទ្ធិសាសនាចូលទៅស្ថិតនៅក្នុងជីវភាពគ្រប់រូប, ពួកយោគាវចរដែលធ្វើសមាធិកម្មដ្ឋាន ជាបុគ្គលដ៏ឧត្តមស្ថិតនៅក្នុងក្រុមដែលមានតម្លៃក្នុងប្រជុំជន ហើយជាទីនិយមរាប់អាននៃពួកនេះ ដូចខាងបច្ចិមទ្វីបគេតែងរាប់អានសរសើរនូវពួកធនាគារិក (Banquier) និងអ្នកស្ទាត់ជំនាញខាងប្រដាល់ ។ នៅក្នុងពិភពលោកគ្មានប្រជារាស្ត្រណាស្លូតត្រង់ ដូចប្រជារាស្ត្រដែលកាន់ព្រះពុទ្ធសាសនា[១] ឡើយ គឺប្រជារាស្ត្រដែលមានចិត្តសន្តោសមេត្តាផ្សាយ

---

១ គេអាចតបតមកខ្ញុំវិញបានថា មានប្រជារាស្ត្រដែលកាន់ព្រះពុទ្ធសាសនាខ្លះ ច្រើនធ្វើសង្គ្រាមនឹងគ្នាទៅវិញ-មក ដូចជាប្រជារាស្ត្រ ចិន, ជប៉ុន ហើយប្រជារាស្ត្រជប៉ុនត្រឡប់ជាប្រជារាស្ត្រពេញចិត្តខាងការធ្វើសង្គ្រាមទៅវិញ ។ ខ្ញុំអាចឆ្លើយទៅវិញថាប្រទេសទាំងពីរពិតមែនតែមានអ្នកកាន់ព្រះពុទ្ធសាសនាដោយភាគច្រើន, បើតាមខ្ញុំយល់ថា មិនមែនជាប្រទេសដែលនិយមកាន់ព្រះពុទ្ធសាសនាពេញលេញទេ ។

ក្នុង . . .

ជ្រួតជ្រាបជាគ្រឹះ ដែលមានចិត្តប្រាសចាកសេចក្ដីស្អប់ អប់រំមកយូរហើយ ៗ ត្រូវតែយើងចាំជាក់ពីអតីតប្រវត្តិ, កាលពួកទីបេត៍តាំងនៅជាអនារ្យជន (Barbares) ឬពួកមង់កូលក្នុងរដ្ឋកាលព្រះបាទសង់សិសទ័ន ដែលមិនទាន់ចូលស៊ប់ក្នុងព្រះពុទ្ធសាសនានៅឡើយ, ឥឡូវព្រះពុទ្ធ-សាសនាបានរចនាអធ្យាស្រ័យជនជាតិទាំងនេះ ទៅជាអ្នកស្លូតត្រង់ក្នុងបច្ចុប្បន្នសម័យ ៗ បើចិត្តសទ្ធាចំពោះពុទ្ធសាសនិកជនមិនទាន់មានទម្រង់ជាសង្គម មានសភាពដែលយើងធ្លាប់ស្គាល់ស្រាប់, ពួកនេះបានព្យាយាមអប់រំមេត្តាចិត្តចំពោះសព្វសត្វ, ការពារនូវសេចក្ដីទុក្ខលំបាករបស់សត្វបានដោយអន្លើ ៗ ។ គឺចិត្តមេត្តានោះឯង ដែលជាមូលហេតុ

---

នៅប្រទេសជប៉ុន, សាសនារបស់រដ្ឋគឺសាសនា "ស៊ីងតូ" ដែលកើតឡើងពីក្បួនរណសាស្ត្រខាងពួក "សាមូរ៉ៃ" ជាបុគ្គលអ្នកស្នេហាជាតិ, ជាវីរជន ពេញចិត្តខាងការធ្វើសង្គ្រាម បានអប់រំជាតិជប៉ុនឲ្យមានកិត្តិសព្ទល្បីល្បាញខាងរណសាស្ត្រ ព្រមទាំងមានចិត្តសប្បុរស តែងជួយដោះទុក្ខអ្នកលំបាក អ្នកមានទោសភ័យ ។ ព្រះពុទ្ធសាសនា ជប៉ុនច្រើនមានអានុភាពផ្សាយទៅកាន់ពួកគណៈសេន (Secte Zen) ។ នៅប្រទេសចិន ព្រះពុទ្ធសាសនាគឺជាវត្ថុមួយរបស់សាសនា មិនអាចចូលទៅជ្រាបឲ្យជ្រៅដល់ប្រជាករចិនបានទេ; តែប្រជារាស្ត្រចិនជាមនុស្សស្លូត ស្អប់ខ្ពើមសង្គ្រាម ហើយគ្រាន់តែជាអ្នករងនូវសង្គ្រាម ដោយជៀសវាងមិនផុតប៉ុណ្ណោះ ។ មនុស្សដែលនាំឲ្យមានសង្គ្រាម កងទ័ព សុទ្ធតែមនុស្សថោកទាប អាក្រក់ពាលទុច្ចរិត ជាសមាសភាពក្នុងចំណោមប្រជាជនទាំងមូល ហើយពួកចិនដែលស្ថិតនៅក្នុងត្រកូលខ្ពស់ តែច្រើនប្រមាថមើលងាយពួកទាហាននេះ ។ ត្រូវយើងបន្ថែមសេចក្ដីទៀតថាប្រទេសទាំងពីរនេះ, ច្រើនឃើញខាងប្រទេសជប៉ុន តែងក្រេបយករសជាតិស៊ីវីល្ឡៃពីពួកបច្ចិមជាតិ ដែលផ្ទេរច្រើនតែសភាពលាមក មកឲ្យប្រទេសទាំងពីរ ។

នាំឲ្យកើតនូវធម៌ស្លូតត្រង់ល្អ, មានឥទ្ធិពលដូចជាបុប្ផាផ្សាយគន្ធពិដោរក្រអូបឈ្ងុយឈ្ងប់ ដែលអ្នករស់នៅៗ ប្រទេសកាន់ព្រះពុទ្ធសាសនាធ្លាប់បានជួបប្រទះ ។ គឺជាអាកប្បកិរិយាសំដែងនូវសេចក្ដីមេត្តាចំពោះសត្វលោកទូទៅ តាំងពីសត្វតូចឡើងទៅ, មេត្តាដែលជ្រួតជ្រាបទៅក្នុងទឹកបេះដូង រមែងតែរទន់ជានិច្ចផ្សាយចេញតាមភ្នែក, តាមមាត់ញញឹម, តាមការទទួលបដិសណ្ឋារៈដោយមេត្រីដែលជាហេតុឲ្យកើតសន្តិភាពនេះ មានសភាពផ្ទុយនឹងការតស៊ូដើម្បីជីវិត (Struggle for life) ចំពោះជាតិឯទៀតដែលអប់រំមកយូរហើយ ។ មិនមែនតែប៉ុណ្ណោះទេ, ចំពោះធម៌ស្លូតត្រង់, មេត្តានោះ ប្រជាក្រស្តនៅមានការព្យាយាមជានិរន្តរកាល ដើម្បីតស៊ូនឹងអត្តទត្ថភាព (Egoisme) ដោយមិនបានគិតថា មានតែខ្លួនអញមួយស្ថិតនៅក្នុងលោក, ថាមិនត្រូវឲ្យលោកទាំងមូលប្រព្រឹត្តឬតាមឆន្ទៈរបស់ខ្លួនអញ ឬតាមទំនើងចិត្តខ្លួនដែលត្រូវការ ។ នេះជាគុណធម៌ដ៏ឧត្តមខាងព្រះពុទ្ធសាសនា ។

ខ្ញុំបានពិសោធចំពោះបាឋកថានេះ ដោយប្រៀបធៀបសាសនាទាំងពីរ, វប្បធម៌ទាំងពីរ, យោបល់នៃជីវភាពទាំងពីរថា តើយើងទាំងពីរអាចរចនាវគ្គទាំងពីរឲ្យវេញបញ្ចូលមូលគ្នាតែមួយបានឬ? តើយើងអាចធ្វើឲ្យវគ្គទាំងពីរជួយឧបត្ថម្ភគ្នាទៅវិញ-មក ឬព្រមព្រៀងគ្នាជាឯកច្ឆន្ទបានឬ? ។ នេះជាបញ្ហានៃការគមនាគមន៍ ចំពោះបូព៌ាទ្វីបនឹងបច្ចិមទ្វីប ។

ឡាក់គោលជាបឋមដើម្បីឲ្យប្រជាកស្ត្រទាំងពីរយោគយល់ស្រឡាញ់គ្នាទៅវិញទៅមក គឺត្រូវតែឲ្យអ្នកទាំងពីរស្គាល់គ្នាជាមុនសិន, ហើយត្រូវសិក្សាឲ្យយល់ច្បាស់លាស់នូវវប្បធម៌និងសាសនាទាំងពីរខាង ។ តែការទាក់ទងនេះចំនួនពីរសតវត្សរ៍មកហើយ, ពួកខាងបូព៌ាទ្វីបនឹងពួកខាងបច្ចិមទ្វីប មិនទាន់ស្គាល់គ្នាពេញលេញទៅវិញទៅមកនៅឡើយ, ពិតមែនតែពួកបូព៌ាទ្វីបស្គាល់នូវស៊ីវិឡៃឬអារ្យធម៌ខាងយើងច្រើន ជាងយើងស្គាល់អារ្យធម៌ខាងបូព៌ាទ្វីប ។ ការដែលល្ងង់មិនស្គាល់នូវរឿងរ៉ាវខាងបូព៌ាទ្វីប មកពីការយល់ថា ពួកអ្នកបច្ចិមទ្វីបតាំងខ្លួនជាជាតិប្រសើរជាងពួកអ្នកបូព៌ាទ្វីប ដែលយើងបានសំដែងហេតុឲ្យជ្រាបសព្វគ្រប់មកហើយ ។ ពួកនេះយល់ថា: ស៊ីវិឡៃរបស់ខ្លួនមានតម្លៃជាងគេ, យល់ថាការស្គាល់នូវស៊ីវិឡៃនៃបូព៌ាទ្វីបជាការឥតប្រយោជន៍, ហើយយល់ថាស៊ីវិឡៃខាងបូព៌ាទ្វីបនេះមុខជានឹងសាបសូន្យ ហើយយកស៊ីវិឡៃខាងបច្ចិមទ្វីបមករចនាលោកកតាំងមូលឲ្យបានឡើងទៅកាន់សន្តិភាព ។ រឿងនេះ ដូចកាលអ្នកនិពន្ធយ៉ាងចំណានម្នាក់នាមលោក គឺថ (Gœthe) ដែលបានតែងរឿងរ៉ាវពីជាតិភីស្ទាំង (Phlistins) ដែលលោកស្គាល់ចរិយារបស់ជាតិនេះពិតប្រាកដ ។

ចំណែកខាងព្រះពុទ្ធសាសនា, ពួកអ្នកបច្ចិមទ្វីបគេមិនសូវទទួលស្គាល់ ហើយថែមគេយកទៅរចនាឲ្យខុសពីគោលការណ៍ដើមផង ។ ពួក

បេសកជនខាងគ្រិស្តសាសនាដែលនាំ "សាសនាពិត" មកប្រដិស្ឋាន នៅអាស៊ីទ្វីបនោះ មិនដែលស្គាល់នូវវប្បធម៌ ព្រមទាំងសាសនានៃប្រជាកស្រុកខាងបូព៌ាទ្វីប ។ ពួកនេះមានឆន្ទៈបង់ដឹកនាំពួកអ្នកបូព៌ាទ្វីបឲ្យចូលខាងសាសនារបស់ខ្លួន ហើយមានវិជ្ជាខាងសាសនាតែត្រឹមសញ្ញាណជាបឋមវិជ្ជា ដែលបានរៀនបេះចាំនូវគ្រិស្តសាសនស្ថាន ។ ពួកនេះ ហៅពួកអ្នកដែលកាន់សាសនាក្រៅពីខ្លួនថាជាពាហិរសាសនិកជន (Paien) ហើយថាគេជាទិដ្ឋិវិបត្តិ (Superstition) ព្រោះតែទំនៀមនៃសាសនាគេគឺខ្លួនមិនអាចយល់បាន ព្រមទាំងយល់ថាពួកបូព៌ាជាតិជាពួកអនារ្យជន (Sauvages) ។ ខ្ញុំយល់ថាគួរបំពេញករណីយកិច្ចឲ្យប្រសើរជាងនេះទៅទៀត ។ យើងបានឃើញថា ចំពោះសីលធម៌ ឬបរមត្ថវិជ្ជា ឬសាសនវិជ្ជានៃព្រះពុទ្ធសាសនា មិនមែនជាមានសភាពថោកទាបជាងព្រះគ្រិស្តសាសនានោះទេ ។ ហេតុម្តេចក៏ទៅជាមានឆន្ទៈចង់ធ្វើឲ្យវិនាសនូវពុទ្ធសាសនា ដែលគេទុកជាសាសនាឯកក្នុងលោក ហើយជាបុព្វហេតុនៃវប្បធម៌ខាងចុងបូព៌ាទ្វីប ព្រមទាំងស៊ីវិល្យ សិល្បវិជ្ជា, អក្សរសាស្ត្រ និងធម៌មេត្តា, ស្លូតត្រង់, សន្តិភាពនោះទៅវិញ? ហេតុម្តេចក៏ចង់យកសាសនាដទៃមកជំនួសព្រះពុទ្ធសាសនាទៅវិញ ? ដែលជាសាសនាកើតចំរើនវ័យវិល្បនាការនៅសមុទ្រមេឌីតេរ៉ាណេ ជាមូលហេតុឲ្យកើតលោកវិជ្ជា, តក្កវិជ្ជា ព្រមទាំងយោបល់ខាងទស្សនវិជ្ជា គឺជា

ខាងទស្សនវិជ្ជា គឺជាវត្ថុក្រៅពីចិន្តានៃអ្នកបូព៌ាទ្វីប ដែលបាននាំមកនូវធម៌សូត្រត្រង់ ឬសទ្ធិភាពចំពោះពួកអ្នកបច្ចិមទ្វីប? ។ នេះជាគោលការណ៍ពិសោធន៍ ដែលគ្រិស្តសាសនាមិនអាចចូលទៅសមាគមគប់យ៉ាងស្និទ្ធចំពោះពួកបណ្ឌិតខាងព្រះពុទ្ធសាសនា, ចំពោះប្រទេសដែលកាន់ពុទ្ធ-សាសនាដោយមាំមួន ។ ពួកគ្រិស្តសាសនិកជនអាចដឹកនាំបានតែពួកជនល្ងង់ខ្លៅ ដោយបង្ហាញនូវព្រះគ្រិស្តសាសនាផ្នែកខាងមនោសញ្ចេតនានឹងខាងពិធីក្រៅដែលមិនសូវមានសារៈប្រយោជន៍ ។

ខ្ញុំយល់ថា: មិនត្រូវដឹកនាំពួកអ្នកបូព៌ាទ្វីបឲ្យប្រតិបត្តិតាមសាសនាដែលមានសភាពក្រៅពីគំនិតអធ្យាស្រ័យនៃពួកនេះទេ ត្រូវតែដឹកនាំឲ្យពួកនេះយល់ច្បាស់នូវព្រះពុទ្ធសាសនាទៅវិញ ។ ការដែលយល់ខុស, ការដែលឃ្លាងគំនិតខាងផ្លូវសាសនា, កិច្ចដែលមិនស្គាល់ច្បាស់លាស់នូវសីលធម៌នឹងសង្គមនៃពួកអ្នកបូព៌ាទ្វីប កើតឡើងដោយហេតុមកពីពួកនេះមិនសូវយល់នូវសាសនារបស់ខ្លួន ។ ពួកពុទ្ធសាសនិកជន ដែលជាអ្នកមានសទ្ធាមាំមួនក្នុងសាសនា ចំពោះតែជនណាដែលមិនទាន់ដែតជ្រាបនូវវិជ្ជាខាងបច្ចិមទ្វីប, ឯពួកខាងគ្រិស្តសាសនាមានច្រើនជាអនេកប្បការតែនៅមិនទាន់ចេះដឹងគ្រប់គ្រាន់បរិបូណ៌ល្មមដឹកនាំពួកបូព៌ាជាតិ ឲ្យបានចំរើនខាងផ្លូវប្រាជ្ញា ។ ក្នុងខនេះ, ចំពោះសហការនៃបូព៌ាទ្វីបទៅកាន់បច្ចិមទ្វីបដែលនឹងមានផលដ៏ប្រសើរ គឺមកពីពួកបច្ចិមជាតិចេះប៉ុនប្រសប់

អប់រំពួកបព្វជិតឲ្យមានចំណេះខាងរបៀបវិជ្ជាសាស្ត្រ, ក្បួនភាសា-សាស្ត្រ និងជីវសាស្ត្រ (Philologie) ព្រមទាំងរចនាជនជាតិនេះ ឲ្យយល់ច្បាស់នូវកិច្ចការទាំងពួង ដែលពួកជំនាញខាងជាតិអឺរ៉ុបបានស្រាវជ្រាវ ចំពោះវិជ្ជាអក្សរសាស្ត្រខាងព្រះពុទ្ធសាសនា ៗ នេះហើយដែលប្រទេសបារាំងមានបំណងចង់ធ្វើឲ្យសម្រេចប្រយោជន៍ក្នុងរឿងនេះ បានជាស្ថាបនាក្នុង គ. ស. ១៩៣១ នៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ ដែលមានផលដ៏ប្រសើរ ចំពោះការរៀបចំជាថ្មីនូវលទ្ធិពុទ្ធសាសនាខាងហីនយាននៅកម្ពុជរដ្ឋ ៗ វិជ្ជាស្ថាននេះ, បានផ្ដើមបោះពុម្ពព្រះត្រៃបិដក ដែលបានបាត់ធ្វើឲ្យមានរបៀបរៀបរយ ព្រមទាំងសៀវភៅនឹងអត្ថបទខាងព្រះពុទ្ធសាសនាជាភាសាខ្មែរ ចេញផ្សាយរហូតគ្រប់ភូមិ-ស្រុក-និគមជនបទទាំងជិតឆ្ងាយ នឹងបើកសេរីភាពឲ្យពួកភិក្ខុ-សាមណេរនៅវត្តក្រៅនិមន្តមករៀននៅព្រះរាជធានីភ្នំពេញចំនួន ៣ ឆ្នាំ (១) រួចត្រឡប់ទៅវត្តក្រៅសព្វៗ អង្គ ដើម្បីនឹងធ្វើគ្រូបាអាចារ្យផ្សាយនូវធម៌វិន័យចំពោះប្រជាកស្ត្រទាំងអស់ ៗ

នេះជាស្នាដៃដែលគួរធ្វើ ដើម្បីនឹងឲ្យបព្វជិតទូបនឹងបច្ចុមទូបឲ្យមានការទាក់ទងកាន់តែជិតស្និទ្ធស្នាលដោយមេត្រីភាព, ពួកអ្នកបច្ចុមទូបក៏អាចធ្វើការនេះប្រកបដោយអភិជនភាព ហើយមានប្រយោជន៍សំខាន់

១ បើតាមមាត្រា ២០ នៃអារេតេលោកគូវែរណឺរសេណេរ៉ាល់លេខ ៨.៣៥១ ចុះថ្ងៃទី ១ ធ្នូ ១៩៤២, កំណត់ ៤ ឆ្នាំទើបប្រឡងចេញបាន ។

ចំពោះមនុស្សជាតិទាំងមូល យ៉េបេះរៀបចំការបលនាចំពោះសហការទឹង ព្រះសង្ឃខ្មែរឲ្យមានដំណើរទៅកាន់វឌ្ឍនភាព, មិនត្រូវទៅគិតបង្ខំផ្លាស់ប្ដូរសន្ដានចិត្តនៃមនុស្សជាតិដែលកាន់ព្រះពុទ្ធសាសនាឲ្យទៅជាចរិតនិស្ស័យខាងគ្រិស្ដសាសនា ដែលជាសាសនាមិនអាចយកមកធ្វើឲ្យពួកអ្នកបូពា-ទ្វីបមានចិត្តជ្រះថ្លាទៅបានដោយងាយ ។ រួចការដែលផ្សាយអំពីបច្ចិមទ្វីបនូវអនារ្យធម៌ក្នុងមហាសង្គ្រាមសាកលលោកទីពីរ ហើយមន្ដអានុភាពទៅគ្រប់ប្រទេស នាំឲ្យពួកអ្នកបច្ចិមទ្វីបមានចិត្តអន់ថយត្រង់កិច្ចស្មើស៊ីវិល្សខ្លួនឲ្យយកមកអប់រំពួកអ្នកបូពាទ្វីប ។

បច្ចិមទ្វីបកាន់ខាងគ្រិស្ដសាសនា នឹងបូពាទ្វីបកាន់ខាងពុទ្ធសាសនា មានផលប្រយោជន៍ដ៏សំខាន់ត្រង់ការជួយឧបត្ថម្ភគ្នាទៅវិញទៅមក, មិនត្រូវធ្វើសង្គ្រាមគ្នាទេ ; ពួកខាងបច្ចិមទ្វីបច្រើនមានបំណងទៅកាន់វឌ្ឍន-ភាពខាងជាតុនិយម, ខាងថាមភាព, ខាងការទុកចិត្តចំពោះខ្លួន, ខាងការស្អប់ខ្ពើមផ្លូវប្រាជ្ញា, ខាងការបំណងម៉ាំរបស់ខ្លួន ហើយនឹងការរំលោភបង់ឲ្យប្រទេសដទៃនៅក្រោមបង្គាប់បញ្ជាខ្លួន ។ អំពើនេះធ្វើឲ្យពួកបច្ចិមជាតិមិនអាចទទួលនូវលំអនៃស៊ីវិល្ស ដែលមានដំណើរទៅកាន់ផ្លូវប្រាជ្ញាតែម្យ៉ាងឡើយ ។ កិត្យានុភាពក្នុងការប្រើកំឡាំងមានសភាពសម្បើមអស្ចារ្យនោះ គឺពួកបច្ចិមជាតិពេញចិត្តខាងសភាពសុខស្រួលកាយ, សភាពដើតដោមក្នុងលោក, ព្រមទាំងការសប្បាយខាងវត្ថុធាតុ

នឹងការសប្បាយដោយកាមារម្មណ៍ ហើយអាចផ្ទេរនូវអានុភាពខ្លាំងក្លាពន់ពេកឲ្យមកដល់នានាប្រទេសខាងបូព៌ាទ្វីប ។ មានបុគ្គលជាច្រើននាក់ ច្រើនភ្លេចកិច្ចការខាងផ្លូវប្រាជ្ញា ព្រោះធ្វើចិត្តឲ្យជាប់ចុះស្លុងទៅក្នុងគ្រឿងចក្រ, ពិតមែនតែគ្រឿងនោះ ជាវត្ថុអាចសម្លាប់ខ្លួនបាន, នាំឲ្យកើតសង្គ្រាម, សេចក្ដីវរឹកខាងសង្គម ហើយនឹងភយន្តរាយផ្សេងៗដែលបច្ចិមទ្វីបទុកជាការៈមួយ តែងអូសជាប់ស្អិតពីក្រោយពលភាពរបស់ខ្លួនទៅជាមួយផង ។ គេអាចសរសើរ ហើយក្រមនឹងធ្វើបាននូវប្រទេសខាងអាស៊ីទ្វីបដែលរក្សាទុកនូវវិញ្ញាណក្ខន្ធដ៏បរិសុទ្ធស្អាត, ជាទីជ្រកអាស្រ័យនៃសន្តិភាពក្នុងពិភពលោកដែលកំពុងកន្លល់ជាខ្លាំង, ព្រមទាំងឃុំគ្រងស្ថានភាពរបស់ខ្លួនឲ្យនឹងនួនអស់យូរកាល ស្ថិតនៅក្រោសំណាញ់នៃស៊ីវៃល្យបច្ចិមទ្វីបនឹងកំស្ទួលអាក្រក់ ។ តែបើតាមខ្ញុំស្មានថាមុខជាមិនយូរទេ ចៀមញីត្រូវចចកបរិភោគជាមិនខាន ; តែសូមឲ្យវិនាសជីវិត មិនឲ្យវិនាសវិញ្ញាណក្ខន្ធឡើយ ។

ចប់សន្និសីទលោកវេជបណ្ឌិតមីតូក៍

## ពន្លឺអាស៊ីទ្វីប

## វគ្គទី ៣

### La Lumière de l'Asie

លោក ស៊ើ-អេតវិន អារណូលត៍ តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

ឋមទាហានយាម សឹងមានស្គរជ័យក៏វាយជាសញ្ញាផ្សាយដំណឹង ក្នុងពេលដែលព្រះសិទ្ធត្ថស្តេចយាងមកដល់ ៗ នៅទីនោះ មានពួកព្រះរាជវង្សានុវង្សជាច្រើនយាងទៅរង់ចាំទទួល នឹង សំដែងការគោរពជាទំនៀម ព្រមទាំងមាននាងនាដកាចាំបាចបុប្ផាគ្រប់យ៉ាង នឹង កំប្រៀងថ្វាយជាព្រះកិត្តិយស, ព្រះទីនាំងអស្សតរដែលព្រះសិទ្ធត្ថគង់មក នឹងត្រូវដើរលុយគំនរផ្កាកុឡាប នឹងបាល់សាមីន (Balsamine) ប្រមាណត្រឹមជង្គង់ ៗ ក្នុងពេលនោះ វិថីទាំងនេះសុទ្ធតែបញ្ចេញនូវលំអគ្រប់យ៉ាងទូទៅទាំងព្រះរាជធានីទាំងមូល, ឮសូរសព្ទគ្រឹកគគ្រេងដោយភ្លេងតូរ្យតន្ត្រី នឹងសេចក្តីសប្បាយលាន់ឮកងរំពងពាសពេញសព្វអន្លើ ៗ នេះជាព្រះរាជឱង្ការនៃព្រះមហាក្សត្រិយ៍ ដែលទ្រង់ត្រាស់បង្គាប់ឲ្យចាត់ការ, ឯប្រជារាស្ត្រក៏រង់ចាំស្តាប់សព្ទស្គរជ័យ ដែលគេខ្ទរជាដំបូងផ្សាយដំណឹងជាអាណត្តិសញ្ញាថា "ព្រះរាជឱរសស្តេចយាងមកដល់" ៗ.

តែព្រះនាងយសោធរ មានព្រះរាជបំណងចង់ប្រថាប់នៅពីមុខមហាជន ទើបស្តេចឡើងគង់លើព្រះទីនាំងយានទៅកាន់កំពែងជាន់ក្រៅនៃព្រះរាជធានី ជិតសាលាប្រជុំនោះ ៗ នៅជុំវិញមានព្រះរាជឧទ្យានឈ្មោះ "និគ្រោធ" មានរុក្ខជាតិបែល (Bels) និងដើមល្មើ ដែលខាងលើមានដាងត្រសុំត្រសាយខៀវស្ងាត់ ហាលម្ប់ត្រឈឹងត្រឈៃ ដែលគេដាំជាជួរហូរហែ, នៅក្នុងទីផ្ទៃឧទ្យាននោះ មានផ្លូវបត់ក្ងិកក្ងក់ខ្វាត់ខ្វែង ទាំងមានរុក្ខជាតិផ្សេងៗ គ្រប់បែប សឹងមានផ្កាផ្លែ-រីក ទុំស្រស់ស្អាយ, តពីនោះទៅមានថ្នល់នៅពីខាងត្បូង, តាមចិញ្ចើមថ្នល់ដាំសុទ្ធតែរុក្ខជាតិដែលមានផ្ការីកស្គុះស្គាយដែរ ៗ នៅចិញ្ចើមថ្នល់ម្ខាងទៀត នៅក្រៅព្រះរាជធានីនេះ មានខ្ទមពួកប្រជារាស្ត្រជាពួកមានវណ្ណៈទាប (សូទ្រៈ) មានសេចក្តីក្រីក្រលំបាកច្រើន ដែលពួកក្សត្រិយ៍និងពួកព្រាហ្មណ៍ តែងហាមប្រាមគ្នាមិនឲ្យទៅទាក់ទងប៉ះពាល់កាយឡើយ ដោយក្រែងជាប់មន្ទិលសៅហ្មងជិតដោយមក ៗ

ពួកវណ្ណៈទាបនោះ ក៏បានក្រោកពីបច្ចូសសម័យ រង់ចាំដោយចិត្តព្រួយបារម្ភពន់ពេក ហើយក្រឡេកមើលទៅផ្លូវឆ្ងាយលន្លឹមលន្លោច បំណងនឹងឡើងដើមឈើ ក្នុងខណៈដែលបានព្រុសពួស្សូរសម្រែកជ័រទីង ស្គរគ្រប់វត្ត ៗ ដល់គ្មានអ្នកណាមក, ពួកនេះបានរៀបចំគេហដ្ឋានដើម្បីជាកិត្តិយសដល់ព្រះអង្គម្ចាស់ មានការបោសប្រាសសំអាតមុខទីលំនៅ,

ត្រជាងទន់ល័យ, យកស្លឹកពោធិ៍មកដោតជាកម្រង, ដុសខាត់លិង្គម (Lingam) ហើយយកស្លឹកឈើថ្មីទៅរុំព័ទ្ធស៊ុំជាថ្មី ហើយក៏សាកសួរអ្នកដំណើរ តើមានឧបស័គ្គអ្វីដែលកំផកតាមផ្លូវ ដែលព្រះសិទ្ធត្ថទ្រង់យាងមក? ។ ព្រះនាងយសោធរាទ្រង់បានទតទៅពួកវណ្ណៈទាបដោយព្រះចក្ខុស្អាតល្អ តែព្រះទ័យនៅតែព្រួយជាខ្លាំងដូចជាពួកនោះដែរ, ព្រះនាងបានឆ្ងៀងព្រះនេត្រទៅកាន់ផ្លូវខាងត្បូង, ផ្ទៀងព្រះសោតដើម្បីទីងសវនា តើអ្នកដែលមករង់ចាំទទួល បានឲ្យដំណឹងពីពុទ្ធដំណើរនោះយ៉ាងណាខ្លះ? ក្នុងខណៈនោះស្រាប់តែព្រះនាងទ្រង់ទតទៅឃើញបុគ្គលម្នាក់ដើរដោយដំហានរង្គើលៗ ក្បាលកោររុំចីវរលឿងពាក់លើស្មា, ស្លៀកស្បង់ហើយកាន់អម្បែងពងដូចឃ្លោក ដើរសូមទានតាមមាត់ទ្វារគេហដ្ឋាន, ទទួលអាហារគេជូនហើយជូនពរសព្ទសាធុការហើយដើរតទៅទៀត, បើអ្នកណាមិនឲ្យក៏មិនអាក់អន់ស្រពន់ចិត្តអ្វីឡើយ ។ មានបុគ្គលពីរនាក់ដើរពីក្រោយ, ស្លៀកស្បង់លឿង, តែបុគ្គលដែលកាន់អម្បែងនោះមានលក្ខណៈរូបគួរឲ្យគោរពខ្លាច ហើយបញ្ចេញអានុភាពគួរជាទីជ្រះថ្លាពន់ពេកដោយព្រះចក្ខុស្អាតបរិសុទ្ធ; ពួកទាយកទាយិកាដែលបានធ្វើអំណោយអ្វីមួយរួចហើយ ក្រឡេកទៅកាន់បុគ្គលនោះ ដោយសំដែងគារវភាព ហើយមានខ្លះឱនកាយថ្វាយបង្គំ, មានខ្លះទៀតទៅយកទេយ្យវត្ថុមកជូនទៀត, ខ្លះទៀតត្អូញត្អែរថា ខ្លួនក្រគ្មានវត្ថុអ្វីធ្វើទានទឹងគេ,

ព្រោះហេតុដូចនេះ បានជាមនុស្សប្រុសស្រីដើរពីក្រោយបុគ្គលនោះ ពោលខ្សឹបគ្នាថា: "អ្នកណា នេះ? អ្នកណា? តើជាឥស្សីឬ?" ប៉ុន្តែ ដល់បុគ្គលនោះទៅដល់សាលាសំណាក់ហើយ ស្រាប់តែទ្វារដែលមាន បិទបាំងដោយសំពត់ត្រូវគេបើកឡើង ហើយព្រះនាងយសោធរាទ្រង់ បើកស្បៃមុខ តើនឡើងហើយមានព្រះសុរទីយ៍ថា: "ព្រះសិទ្ធត្ថ, ព្រះ អង្គអើយ!" ហើយទ្រង់ព្រះផលនេត្រ ព្រះហស្តទាំងគូរទ្វាប្រណម្យ ហើយទ្រង់ដួលសោយសោកាដិតព្រះបាទាព្រះសម្មាសម្ពុទ្ធ ។

ដល់ថ្ងៃក្រោយមក, កាលណាព្រះនាងទ្រង់ព្រួយព្រះរាជហឫទ័យ ជាខ្លាំង បានចូលទៅកាន់ផ្លូវវិសុទ្ធិមគ្គហើយ, មានបុគ្គលខ្លះបានសួរព្រះ សម្មាសម្ពុទ្ធថា: ហេតុម្តេចព្រះអង្គទ្រង់លះបង់នូវតណ្ហាដ៏ស្រឡះពី សន្តានទ្រង់ ព្រមទាំងលះបង់ការប៉ះពាល់នូវរាងកាយស្ត្រី ដែលមាន សម្ផស្សស្រទន់ដូចជាបុប្ផាទាំងឡាយហើយផុតពីកណ្តាប់ដៃនៃមាតុគ្រាម. ព្រះអង្គទ្រង់បណ្តោយឱ្យព្រះនាងទ្រង់ព្រះអាលិង្គន (ឱប) ព្រះអង្គ? ។ ព្រះសម្មាសម្ពុទ្ធទ្រង់តបទៅនឹងបុគ្គលនោះវិញថា: "បណ្តាបុគ្គលទាំង អស់, អ្នកធំតែងជាប់ជំពាក់នឹងសេចក្តីស្នេហា, ដូចអ្នកតូចទាបដែរ ពិត មែនតែសេចក្តីស្នេហានោះ មានសភាពខ្ពស់ផុតជាលោកុត្តរៈ ។ អ្នក ទាំងឡាយ កុំប្រមាថបុគ្គលដែលលះបង់នូវចំណងលោកបាន ទាំងកុំធ្វើ បុគ្គលដែលជាប់ចំណងឱ្យអាក់អន់ស្រពន់ចិត្ត ដោយៈ ប្រិទិយ្យានិកភាព

ខុសចំនួនឡើយ ។ អ្នកអាចជាបុគ្គលសេរីកាបានសម្រេចនូវសេរីភាព (ទិព្យាទិកភាព) ដោយធម៌ខន្តី និងមធ្យោបាយផ្សេងៗ ដែលកើតឡើងដោយឧបាយនៃប្រាជ្ញា ។ ពោធិសត្វ[1] បានបំពេញពុទ្ធការកធម៌បីថ្នាក់ គឺទីមួយ អធិដ្ឋានធម៌, ទីពីរ ពុទ្ធកិច្ច, ទីបី ការសម្រេចនូវសម្មាសម្ពោធិញ្ញាណ ។ អ្នកឃើញទេ ? តថាគតបានប្រព្រឹត្តនូវអធិដ្ឋានធម៌, បំណងរកសេចក្តីសុខ, ស្វែងរកបញ្ញាលោកុត្តរៈ តែបញ្ញាចក្ខុនៃសត្វលោក បិទជិតរកស្មើគ្មាន ។ អ្នកចូររាប់គ្រាប់ល្ហុងខ្មែរក្នុងចម្ការនេះ មានចំនួនប៉ុន្មាន? ក្នុងអតីតកាលកន្លងរំលងមកយូរហើយតថាគតបានទៅចាប់កំណើតជាឈ្មួញនៅតាមមាត់សមុទ្រខាងត្បូង, ចំពីមុខកោះលង្កាដែលសម្បូណ៌ដោយគជ់ខ្យង ។ ក្នុងពេលនោះ, ព្រះនាងយសោធរាបានទៅរួមសុខទុក្ខជាមួយតថាគតនៅភូមិតាមមាត់សមុទ្រនោះ, ព្រះនាងមានរូបឆោមលោមពណ៌ស្អាតដូចសព្វថ្ងៃ ហើយទ្រង់ព្រះនាមលក្ស្មី (Laksmi) ។ តថាគតបានចាំដាក់ថាតថាគតបានធ្វើដំណើរទៅជួញស្រុកឆ្ងាយ ដើម្បីនឹងស្វែងរកអាហារមកចិញ្ចឹមជីវិត ព្រោះគ្រួសារតថាគតក្រលំបាកណាស់ក្នុងពេលនោះ ។ ព្រះនាងបានអង្វរតថាគតថា

---

១ ពោធិសត្វ គឺអ្នកដែលត្រូវត្រាស់សម្មាសម្ពោធិញ្ញាណ តែលះបង់នូវញាណដ៏ប្រសើរនេះ ដើម្បីនឹងយោនយកកំណើតក្នុងវដ្តសង្សារតទៅអនាគត បំណងនឹងសង្គ្រោះដល់សត្វលោក " បើតាមអ្នកបកប្រែ : ពោធិសត្វ គឺជាបុគ្គលកំពុងបំពេញពុទ្ធការកធម៌ តែមិនទាន់បានត្រាស់ដឹងជាពុទ្ធភូមិនៅឡើយ ។

កុំឲ្យទៅ ហើយកុំឲ្យទៅតស៊ូនឹងការគ្រោះថ្នាក់ ដែលកើតនៅលើផែនដី ឬ តាមសមុទ្រ, ហើយពោលថា: "តើនឹងឲ្យផ្ដាច់សេចក្ដីស្នេហារបស់ខ្ញុំម្ចាស់ពីស្វាមី ដែលជាទីពេញចិត្តរបស់ខ្ញុំម្ចាស់បានឬ? ។ គថាគត ចាកចេញពីគេហដ្ឋានទៅស្រុកឆ្ងាយ ដើម្បីនឹងស្វែងរកលាភ, គថាគតបានធ្វើដំណើរទៅតាមផែសមុទ្រ ហើយគថាគតបានរងទុក្ខលំបាកដោយខ្យល់ព្យុះ នឹងការតស៊ូនូវសត្វសមុទ្រ ព្រមទាំងទទួលនូវសេចក្ដីភ័យព្រយគ្រប់យ៉ាង, គថាគតបានគដ់ខ្សែមួយក្ដីចាំងដូចព្រះចន្ទ្រ ដែលមានតម្លៃពន់ប្រមាណ ទាល់តែព្រះមហាក្សត្រិយ៍យកប្រាក់ដែលមាននៅព្រះរាជឃ្លាំងទាំងប៉ុន្មានមកទិញទើបបាន ។ គថាគតក៏ត្រឡប់វិលមកទីលំនៅវិញ, តែក្នុងពេលនោះមានទុព្ភិក្ខភ័យកើតឡើងក្នុងភូមិស្រុក; គថាគតក៏ទៅជាឈឺដោយអត់អាហារ ហើយគថាគតស៊ូធ្វើដំណើរតមកទាល់តែដល់គេហដ្ឋាន ហើយគថាគតបានលាក់គដ់ខ្សែដែលជាវត្ថុវិសេសអស្ចារ្យ ។ តែភូមិដែលគថាគតនៅក៏មានទុព្ភិក្ខភ័យដូចគ្នា, ហើយគថាគតចូលទៅក្នុងផ្ទះ ស្រាប់តែឃើញព្រះនាងដែលរងទុក្ខលំបាកជាអនេកជាងទុក្ខលំបាករបស់គថាគតទៅទៀត ដួលដេកនៅទីនោះជិតអនិច្ចកម្ម, ដោយគ្មានអាហារបរិភោគ ។ ក្នុងពេលនោះគថាគតស្រែកថា: "បើអ្នកណាមានស្រូវ, គថាគតនឹងឲ្យគ្រឿងអលង្ការដ៏វិចិត្រនេះមានដម្លៃនគរទាំងមូល ដើម្បីនឹងជួយសង្គ្រោះជីវិតដល់ព្រះនាង អ្នកណា

ហាំងឲ្យអាហារដល់នាងលក្ខីបរិភោគ   តថាគតនឹងឲ្យគជ់ខ្យងក្លីដូចព្រះចន្ទ្រ" ។ ដល់ពេលដូចនេះ អ្នកដែលនៅជិតខាងក៏បានយកធញ្ញជាតិចំនួន ៣ សែរ[1] (Sères) ហើយក៏យកគជ់ខ្យងនោះទៅ ។ លុះនាងលក្ខីបានរស់រានមានជីវិតឡើងហើយ ក៏ប្រមកកាន់តថាគតថា: "លោកស្រឡាញ់ខ្ញុំម្ចាស់ពិត" ។ តថាគតបានជូរគជ់ខ្យងក្នុងពេលនោះ ដើម្បីនឹងជួយសង្គ្រោះដល់ជីវិតនាង តែគជ់ខ្យងនោះ ដែលតថាគតបានព្យាយាមរកយកបានពីក្នុងសមុទ្រមក គឺជាធម៌ទាន: ១២ (បដិច្ចសមុប្បាទ ១២ ) នឹងផលកុសលមិនអាចធ្វើឲ្យរលត់រលាយ ហើយត្រូវចេនាបុណ្យកុសលនោះទៅកាន់សោកណាភាព ព្រោះជាទានធ្វើដោយគ្មានជាប់តណ្ហា ។ ព្រោះថាដំបូកស្រមោច ម្ដេចឡើយនឹងទៅប្រៀបផ្ទឹមនឹងភ្នំមេរុបាន? ទឹកដែលកើតឡើងដោយទឹកសន្សើម ស្ថិតនៅក្នុងស្នាមជើងគ្រើស ម្ដេចឡើយនឹងប្រៀបផ្ទឹមនឹងទឹកសមុទ្របាន? អំណោយដែលតថាគតបានធ្វើពីកាលនោះ ម្ដេចឡើយមកប្រៀបធៀបនឹងអំណោយដែលធ្វើក្នុងពេលនេះបាន ? ព្រោះហេតុនេះ សេចក្ដីស្រឡាញ់ដែលប្រាសចាកនូវកាមារម្មណ៍ជាព្រហ្មវិហារដ៏ខ្ពង់ខ្ពស់ អាចមានចិត្តទនលំទោនទៅកាន់អ្នកខ្សោយៗពលភាព ដូចជាព្រះបាទនៃនាងយសោធរ នាំមកនូវសន្តិភាពនឹងសេចក្ដីសុខក្នុងពេលនេះដូចនោះឯង ។ (មានត)

---

១ សែរ (Sères) គឺក្រាស់ក្រាល់ មានទំងន់កន្លះលីត្រ ។

## លោកបាលធម៌

# ព្រះបាឡាត់អរិយកស្សប ឃុង-ឈួន

វត្តបទុមវតី ក្រុងភ្នំពេញ

ទេសនាផាក់វិទ្យុឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ រោច ខែមិគសិរ ឆ្នាំកុរនព្វស័ក ព. ស. ២៤៩០ (៤—១—៤៨)

---

## នមត្ថុ រតនត្តយស្ស ។

## ហិរោត្តប្បំយញ្ចេវ លោកំ បាលេតិ សាធុកន្តិ ។

វេលានេះ អាត្មាភាព ត្រូវវេនសំដែងវិទ្យុធម្មទេសនា ចែកជូនអស់លោកសប្បុរសទាំងឡាយស្តាប់ ។

អាត្មាភាព នឹងសំដែង អំពីលោកបាលធម៌ គឺធម៌ជាគ្រឿងឃុំគ្រងរក្សាលោកឲ្យបានល្អ ។ ចុះធម៌អ្វីខ្លះ ដែលឈ្មោះថាលោកបាលធម៌? ហិរិ នឹងឱត្តប្បៈ ឈ្មោះថាលោកបាលធម៌ ។ ហិរិគឺអ្វី? គឺសេចក្តីខ្មាសអំពើអាក្រក់គ្រប់យ៉ាង ។ ចុះឱត្តប្បៈ បានដល់អ្វី? បានដល់សេចក្តីខ្លាចអំពើលាមកគ្រប់បែប ។ ចុះបើគ្រាន់តែខ្មាសនឹងខ្លាចប៉ុណ្ណោះទេ ហេតុអ្វីក៏ឈ្មោះថាឃុំគ្រងរក្សាលោក? ហេតុថា លោកគឺពួកសត្វ ទោះជាគ្រហស្ថក្តី បព្វជិតក្តី បើបានបង្អោនហិរោត្តប្បធម៌នេះ មកដំកល់ទុកក្នុងសន្តាន ហើយប្រតិបត្តិតាមថែមទៀត, គ្រហស្ថ បព្វជិតនោះ អាចសួយសពាំង្គកាយទាំងមូល ឲ្យអណ្តែតឡើងផុតអំពីគំនរនៃសេចក្តីអាក្រក់គ្រប់

យ៉ាង ទឹងកំងកមិនឲ្យសេចក្ដីលាមកកើតឡើងបានទៀត បានជាឈ្មោះថា គ្រប់គ្រងរក្សាលោក ។ តែលោកក្នុងទីនេះ សំដៅយកតែសត្វលោក គឺពួកមនុស្សមួយយ៉ាង ពុំបានពោលដល់សង្ខារលោកនិងឱកាសលោក ឡើយ ។

ឯ ហិរិឱត្តប្បៈ គឺខ្មាសនិងខ្លាចចំពោះអំពើទុច្ចរិត សេចក្ដីប្រព្រឹត្ដ អាក្រក់ផ្លូវកាយ វាចា ចិត្តនេះ បើយើងគ្រាន់តែពោលថាខ្មាស ៗ ខ្លាច ៗ ត្រឹមតែបបូរមាត់ប៉ុណ្ណោះទេ នោះក៏ឥតអំពើដែរ ។ សូមលើក គួយ៉ាងដូចពួកពុទ្ធមាមកជនទាំងគ្រហស្ថបព្វជិត មានមុខងារជាអ្នកកាន់ ក្រិត្យប្រព្រឹត្តវិន័យ តាមផ្លូវពុទ្ធសាសនា, រដ្ឋាភិបាលជន មានមុខងារ ជាអ្នកប្រព្រឹត្តខ្លួនឲ្យតាំងនៅក្រោមរដ្ឋប្បញ្ញត្តិ គឺច្បាប់ដែលគេតែងតាំង ឡើងសម្រាប់ដែន ។

បព្វជិត បើពុំហ៊ានប្រព្រឹត្តកន្លងវិន័យពុទ្ធប្បញ្ញត្តិ ព្រោះខ្មាសគេ ព្រោះខ្លាចឧបជ្ឈាយាចារ្យផ្ដន្ទាទោស និងប្រជានិករគរហានិន្ទាប៉ុណ្ណោះ ទេ លុះដល់វេលាស្ងាត់កំបាំងក៏តាំងប្រព្រឹត្តល្មើសកន្លងវិនយបញ្ញត្តិ សិក្ខាបទធំ-តូចតាមតែអំពើចិត្តទៅ ។

គ្រហស្ថជាពុទ្ធសាសនិកជន បើខ្មាស ខ្លាចដូចជាស្ត្រីក្រមុំមានរូប ល្អ ពុំហ៊ានចេញឆ្ងាយពីបន្ទប់ ដោយខ្លាចគេឯងមើលឃើញ ពុំនោះ សោតដូចកូនប្រុស-ស្រីឬកូនសិស្សដែលខ្មាសខ្លាចមាតាបិតាគ្រូបាអាចារ្យ

ផ្តន្ទាទោស ហើយពុំហ៊ានប្រព្រឹត្តអំពើអាក្រក់ លុះកំបាំងបេះតែធ្វើតាមចិត្តទៅ ។

ចំណែករដ្ឋាភិបាលជន បើខ្មាសខ្លាចពុំហ៊ានប្រព្រឹត្តល្មើសកន្លងរដ្ឋប្បញ្ញត្តិដោយគំនិតគោង ព្រោះខ្លាចមហាសព្រធិបតិជន លុះស្ងាត់កំបាំង ក៏តាំងរឹបជាន់សង្កត់សង្កិនទៅតាំងអំណាច ។

ការខ្មាស ការខ្លាចបែបនេះ ពុំប្រសើរឡើយ ព្រោះជាអំពើដែលនាំឲ្យក្តៅក្រហាយខាងក្រោយ ។

លុះតែខ្មាស ខ្លាចផុះឡើងអំពីដួងចិត្តរបស់ខ្លួន ចំពោះទោសកំហុសដែលកើតឡើងអំពីការល្មើសវិនយប្បញ្ញត្តិ ឬរដ្ឋប្បញ្ញត្តិ ទាំងផ្លូវលោក ផ្លូវធម៌ ដោយនឹកដល់ជាតិកំណើត វយៈ សេចក្តីចំរើន, សេចក្តីក្លៀវក្លាអង់អាចនឹងសេចក្តីបេះដូងរបស់ខ្លួន ព្រមទាំងខ្លាចដល់ការតិះដៀលខ្លួនដោយខ្លួនឯង ខ្លាចអ្នកដទៃគេបោនិន្ទា ខ្លាចព្រះរាជអាជ្ញា ខ្លាចគតិដ៏អាក្រក់ ហើយពុំធ្វើអំពើទុច្ចរិត ទើបរាប់ជាខ្មាស - ខ្លាច អាចជួយគ្រប់គ្រងអភិបាលគាំទ្រខ្លួនឲ្យបានសេចក្តីសុខ - ចំរើន នឹងសេចក្តីល្អ ទាំងក្នុងបច្ចុប្បន្ននេះនឹងអនាគត ព្រមទាំងឲ្យរួចផុតអំពីសេចក្តីអាក្រក់ទៅបាន ។ សមតាមលំអានពុទ្ធភាសិតថា ធម្មោ ហវេ រក្ខតិ ធម្មចារឹ "ធម៌ (គឺហិរោត្តប្បៈ) រមែងរក្សាអ្នកប្រព្រឹត្តធម៌" ន ទុគ្គតឹ គច្ឆតិ ធម្មចារី "បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ" ។ ព្រោះហេតុនេះ ហិរិនឹងឱត្តប្បៈ ទើបបានឈ្មោះថាលោកបាលធម៌ ។

ហិរិនឹងឱត្តប្បធម៌នេះ បើអស់លោក-អ្នក ទាំងគ្រហស្ថ-បព្វជិត បានបង្អោនមកទុកក្នុងចិត្ត ឬបានប្រព្រឹត្តឲ្យល្អហើយ អាចបត់បង្វិលទឹកចិត្តគំនិតនឹងភ្នែករបស់លោកអ្នកទាំងឡាយ ឲ្យញញឹមញញែមរីករាយ ឈមមុខទៅរកគ្នាបានពល់ទិវារាត្រី ។

កាលបើអស់លោក-អ្នក ដែលជាអ្នកស្រឡាញ់ ជាតិ សាសនា មហាក្សត្រិយ៍បានជ្រាបថាធម៌នេះ ពិតជាធម៌រក្សាលោកឲ្យបានល្អហើយ ក៏សូមខ្ជាក់ចោលនូវកំហាកពោលគឺសេចក្តីអាក្រក់ ផ្លូវកាយវាចាចិត្ត ចេញពាកខ្លួនសន្តានឲ្យដាច់ៗទៅ ហើយសូមខំប្រឹងកសាងបណ្តុះឬបំពេញ ហិរោត្តប្បធម៌ ដែលជាសញ្ញាករណៈរបស់យើងទាំងអស់គ្នា ឲ្យគ្រប់គ្រាន់ឡើង ដើម្បីនឹងបានជាឧត្តមគតិមួយ ដល់យុវនារី យុវជនដែលជាអ្នកដើរតាមក្រោយ យកជាតម្រាប់ផង ។

ទីបំផុតនេះ អាត្មាភាពសូមជូនពាក្យពីរបទ ផ្ញើទុកចំពោះអស់លោក ជារដ្ឋាភិបាល នឹងប្រជានិករ ព្រមទាំងយុវនារី យុវជនរួមជាតិថា: សូមកុំភ្លេចសច្ចៈ (សេចក្តីពិតត្រង់) ហើយកុំលះបង់ វិរិយៈ (សេចក្តីព្យាយាម) ក្នុងកាលដែលលោកអ្នកបានបំពេញនូវហិរោត្តប្បធម៌គ្រប់គ្រាន់ហើយនោះ ព្រោះសច្ចវិរិយធម៌នេះហើយ ដែលអាចសួយជួយជាតិ សាសនា មហាក្សត្រិយ៍ ព្រមទាំងមាតុភូមិរបស់យើង ឲ្យដំណើរជឿនលឿនទៅ កាន់អារ្យធម៌ខាងអនាគត ។

ហេតុនេះ សូមអស់លោកជាមិត្តភាព ភាតរភាពទាំងឡាយ ទោះជាគ្រហស្ថក្តី បព្វជិតក្តី ដែលមានសមត្ថភាពយ៉ាងគ្រប់គ្រាន់ សូមកាន់នូវសច្ចៈ សេចក្តីពិតត្រង់ ចំពោះមុខការរបស់ខ្លួន, សូមមានវីរិយៈ សេចក្តីប្រឹងប្រែងខ្នះខ្នែង ចំពោះមុខការរបស់ខ្លួន ឲ្យម៉ឺងម៉ាត់ឡើង, ព្រោះឱកាសនេះហើយដែលជាឱកាសមួយ គួរអស់លោក-អ្នកខំបំពេញសច្ចវីរិយៈ ទើបនឹងអាចបំបាត់នូវអំពើអយុត្តិធម៌ អំពើលញ្ចការរបស់ទុជ៌ន, មោហជនបានដោយងាយ ។

អាត្មាភាពសូមថ្វាយព្រះពរ ព្រាជសិរីសួស្តីជយមង្គលព្រះជន្មសុខគ្រប់ប្រការ សូមកើតមានដល់ព្រះបាទសម្តេចព្រះបរមបពិត្រព្រះរាជ-សម្ភារដ៏ទ្រទ្រង់នូវព្រះគុណធម៌មហាប្រសើររាល់ទិវារាត្រី ព្រមទាំងប្រជានិករកម្ពុជរដ្ឋគ្រប់ភូមិ-ជាន់ សូមឲ្យបានប្រកបសុវត្ថិមង្គលសួស្តីតរៀងទៅ ! ។

សំដែងមកក្នុងលោកបាលធម៌ សូមសន្មតជាចប់ដោយសង្ខេបប៉ុណ្ណេះ ឯវំ ។

ចប់

កាវីជអ្នកាសិត

## មហាឱម-ត៉ាគ្រី

ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង រៀបរៀង

ឃុន-សុវត្ថិវេទី ឃូរ-អ៊ុន ពិនិត្យកែ

---

### ទោសនៃសុរា

អ្នកប្រមឹក ផឹកសុរា នឹងមេរ័យ
តែងហិនហោច ខូចហិនហៃ ទ្រព្យសម្បត្តិ
រលត់ប៉ុង រលើងខ្ចាយ រលាយខ្ចាត់
វិនាសបង់ វិនាសបាត់ ឥតសេសសល់ ។
អ្នកប្រមឹក តែងប្រមូល ចូលចិត្តឈ្លោះ
ពោលគំរោះ ពាក្យគំរក់ លាមកខ្វល់
ជេរបញ្ឆោះ ឈ្លោះបញ្ចោរ កោលាហល
កើតក្តីកាំ នាំបុកផ្តល់ ដល់រដ្ឋបាល(១) ។
អ្នកប្រមឹក ផឹកសុរា ក្លាជាប់ជោក
បណ្តាលរោគ បណ្តុះរូប ឲ្យពិការ(១)
ឲ្យក្តៅហួស ឲ្យប្រួសហាល់ រូបសង្ខារ
ឲ្យងងឹត ខូចវិចារ-ណញ្ញាណ ។

---

១ ក្លួ ល, រ ជាខ្សល់ស្រួយ, អាចយកប្រួកបផ្ទួនញ្ញាបាន ។

អ្នកប្រមឹក តែងស្អុយខូប ហោចកេរ្តិ៍ឈ្មោះ
ព្រសាយសុះ ថាជាមនុស្ស ទ្រុស្តឈ្លានពាន
ដើរផ្តេសផ្តាស ពាសទិសទី ដូចតិរច្ឆាន
អួតអាងប្រាណ បែកព្រោកប្រាជ្ញ ឥតខ្លាចអ្វី ។
ឥតអៀនខ្មាស ឥតបិទបាំង បទគួរបិទ
ជាមនុស្សផិត ជាមនុស្សផុត ជោគកាសី
ធ្វើបញ្ញា ឲ្យអន់ចុះ ឲ្យតុះខ្ចី
ធ្វើស្មារតី ឲ្យវង្វេន កន្ទវង្វេង ។
ការប្រមឹក ជាប្រមុខ ឆ្កួតលីលា
ធ្វើឲ្យកពា ឲ្យថោកទាប ភាពអ្នកលេង
ដើរជ្រក មមកជ្រុល រ៉ៃបុកជ្រែង
តែម្នាក់ឯង ដើរផ្លូវមួយ ពោលទ្រគោះ ។
ពោលអំនួត អួតអំណាច រឿងកាចកោង
ឬកក្រអេង កោងក្រអឺត ប្រឡោះបោះ
ដើរធ្លាក់ថ្កុក ជង្ហុកបឹង ត្រពាំងជ្រោះ
ពោលឡេះឡោះ ស្រែកឡូឡា ព្ឡូងឡាង ។
រ៉ៃបញ្ឆោះ ឈ្មោះបញ្ចោរ កូនប្រពន្ធ
ជេរបង្អន់ ពោលបង្អាប់ ស័ព្ទគ្រេងគ្រាង

កាយបានផ្ទាំង ប៉ុនប៉ាំងបែក ក្រឡប្លាង
មាត់រ៉ូងក៉ង ព្ទរ៉ូសក៉ស ពាសពេញស្រុក ។
ក្អួតចង្អោរ ជុំចង្អាប ក្លិនអសោច៍
ដូចជាខ្មោច ហូរគ្រមង់ សែនអផ្សុក
ជួនជេកជួល ដោយដងព្រៃ សុកម៉ុក
ជួនត្រុក ដើរទទ្រើក ញាប់ញ័រកាយ ។
កាសដៃជើង ឡើងដំនោរ ដោរចំណាប់
អួតពាក់កាប់ អាងតែស្លាប់ ឥតសោកស្តាយ
ឈប់ស្គាល់កូន ចៅប្រពន្ធ ឪពុកម្តាយ
ហ៊ានមើលងាយ កាយជេរលោក អ្នកមានគុណ ។
ប្រឡំឪ ថាជាពួក ម៉ាកកៀនផឹក
ឃើញមុខម៉ែ បែរជានឹក ថាប្រពន្ធ
ត្រង់មិនគួរ ថាជាគួរ បាបជាបុណ្យ
ទោសជាគុណ បុណ្យជាបាប សាបជាប្រៃ ។
ការប្រមឹក នាំប្រមាទ ខាតកុសល
នាំអំពល់ ដល់អំពើ ប្រសើរក្រៃ
នាំបានទុក្ខ បុកម្នេញ ពេញដួងចៃ
នាំចង្រៃ នាំបង្រាស ប្រាសព្រាត់គ្នា ។

នាំថោកទាប ត្រកូលញាតិ ជាតិផៅពង្ស
នាំឲ្យល្ងើ ភ្លើឲ្យល្ងង់ ឆ្កួតពាលា
នាំគេខ្ពើម ល្អើមស្អប់ គេនិន្ទា
នាំវេក បង់ពៀរគ្នា ជាអន្លង់ ។
នាំបាក់កាប់ នាំជាប់គុក នរកគោក
នាំឲ្យសោក វិយោគសៅ យំស្រែង
នាំអន់អប្ប យាប់កេរ្តិ៍ឈ្មោះ យូរអង្វែង
នាំឲ្យក្មេង លែងកោតក្រែង លែងគោរព ។
ការប្រមឹក ៥: ប្រមុខ ទុក្ខបច្ចុប្បន្ន
ឃើញស្រួកាន់ ទាន់ហន់ណាស់ គួរតែឈប់
ឯបរលោក ធ្លាក់ទៅកាន់ ទុគ្គតិភព
គួរកុំងប់ ជាប់សុក ណាខ្មែរអើយ !!! ។

ល្អបគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក
ផឹកស្រាធ្លាប់ស្រេក ជជែកធ្លាប់មាត់

ឌុម - នា៉គ្រិ

## សុភាសិតប្រឌិតរឿង

### ព្រះមហា អ៊ុម - សុខ

សិស្សសាលាបាលីជាន់ខ្ពស់ ថ្នាក់ឆ្នាំទី ៤ "១"

រៀបរៀង

---

# គេជឿ សឹមប្រាប់
# គេស្តាប់ សឹមបរាប
# គេសួរបំអាត្មា សឹមឆ្លើយ ។

សូមសាធុជនត្រង់ត្រាប់ស្តាប់និទាន "បក្សីនិពានរ" ដូចតទៅនេះ:-

នេះនឹងថ្លាថ្លែង    បរាសំដែងកាលគ្រា
ព្រហ្មទត្តរាជា    គ្រងបុរីរម្យពារាណសី ។
កាលនោះមែនមាន    សកុណាមួយប្រាណប្រិមប្រិយ
ជាតិជាបក្សី    គ្រលេងគ្រលោងសោភណា ។
ធ្វើសំបុកនៅ    នាដងព្រៃជ្រៅហិមវា
សែនសុខសប្បា -    ពរពិតឥតមោះមួនមាំ ។
រដូវវស្សា    ភ្លៀងធ្លាក់ពសុធាជោកជាំ
រងាទន្ទ្រាំ    នាំឲ្យសព្វសត្វព្រួយប្រាណ ។
កាលនោះមានស្វា    រងាឯកាឥតស្ថាន

ចរចូលគោះថ្កាន　ប្រញប្រាណរកទីអាស្រ័យ ៗ
បក្សីឃើញស្វា　លំបាកអាត្មាហ្នោះនៃ
ទើបពោលឆាប់វៃ　ថាហៃអឹបឯពានរ ៗ
ដៃជើងបងឯង　ប្រាកដជាក់ស្តែងស្ថាពរ
ដូចមនុស្សនិករ　ម្តេចមិនធ្វើផ្ទះគ្រាន់ជ្រក? ៗ
ស្វាឆ្លើយតបថា　ហៃចៅបក្សាពន្ទុក
ខ្ញុំនឹងស្វែងរក　ធ្វើផ្ទះគ្រាន់ជ្រកម្តេចបាន ៗ
ដៃជើងក្បាលខ្ញុំ　ដូចមនុស្សតូចធំគ្រប់ប្រាណ
ប្រាជ្ញាខ្ញុំគ្មាន　ធ្វើម្តេចសាងស្ថានបាននៅ ៗ
គេលេងគេលោង　ជាសត្វឃិតឃោងមនុស្សខ្លៅ
ពោលថាលំនៅ　មិនមានដល់មនុស្សបែបឯង ៗ
ទើបពោលទៀតថា　ក្តីសុខាមិនស្តែង
ដល់មនុស្សបែបឯង　ជាសត្វមានចិត្តសាហ៊ ៗ
របុិលរបូប　រហ័សផ្លេកផ្លុបចេះណា
ទ្រុស្តមិត្តអាត្មា　ដូចយ៉ាងបងស្វាឯងហ្នឹង ៗ
នៃពានរអើយ　គួរកុំកន្តើយទ្រមឹង
ចូរខំប្រែងប្រឹង　ស្វាធំស្មឹងនឹងគេឡើងទៅ ៗ
កុំខ្ជិលប្រអូស　លះចិត្តស្រមូសហ្មងសៅ

កុំឲ្យមាននៅ ចូរទៅផ្ញើខ្លួនគ្រាន់ជ្រក ។
ពានរគិតថា អាដែនបក្សាព់មក
ពោលពាក្យចំអក ថាអញជាសត្វទ្រស្តមិត្ត ។
បេះមានតែអញ សំដែនផ្កាលផ្កាញ់ឲ្យពិត
រឿងរ៉ាវទ្រស្តមិត្ត ឲ្យឃើញប្រច័ក្សដល់ព់ ។
គិតហើយស្ទុះផ្ទាត ផ្ទោះផ្ទាញលោលោតម៉្មីម៉ា
ចាប់ចុងព្រឹក្សា បោចកោចសម្បុកបក្សី ។
ខូចខាតបែកបាក់ ធ្លុះធ្លាយខ្ចាយធ្លាក់ដាសដី
សត្វស្លាបលែងស្តី ហើរប៉ុពីទីនោះហោង ។
លោកអ្នកចូរស្តាប់ កាន់តាមសណ្ដាប់កុំហ្មង
កុំមោះកន្ទង ពាក្យពិតភាសិតនេះណា ។
ចូរចាំឲ្យជាក់ បក្សីធ្លាយធ្លាក់គ្រះហា
ព្រោះតែអាត្មា ទូន្មានសត្វស្វាល្ងង់ខ្លៅ ។
ពាលស្អប់ឲកទ បណ្ឌិតវៃឆ្លាតប្រជ្ញា,
ឈើគោងមួម៉ៅ តែងស្អប់បន្ទាត់ពេកក្រៃ ។
រុយស្អប់បុប្ផា, កម្រះបក្សាថ្វាថ្ងៃ
ស្អប់លាមកក្រៃ; គួរស្តាប់ឧបមេយ្យនេះហោង ។

អ៊ឹម - ស៊ុខ

# រឿងអាយ៉ោនទាហានចាស់

លោកផេង-ជ្រីវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែពីសៀវភៅ ''កុងអេឡេហ្សង់ ឌុយប៉េអ៊ី រូម៉ាំង ត្វាន្ទី ប៉ា អេ អាដាប្តេ បាប.នវឹន''

(តពីរឿងស្តេចត្រីមក)

---

ក្នុងអតីតកាល មានទាហានចាស់ម្នាក់ ធ្វើការរាជការអស់ចំនួនម្ភៃបួនឆ្នាំ ហើយត្រូវគេបណ្តេញចេញពីមុខងារ ។ ទាហាននេះមាននៅសល់លុយតែប្រាំមួយសេននឹងនំប៉័ងមួយដុំ ។ ហេតុដូច្នេះ វាត្រូវធ្វើដំណើរវិលទៅស្រុកកំណើតវិញ ច្រៀងផងដើរផង ដើម្បីកុំឲ្យបំបាត់សេចក្តីព្រួយ ។ វេលាកំពុងដើរ អាយ៉ោនបានជួបតាចាស់កាន់ឈើច្រត់ពីរនាក់ ។ ឯតាចាស់នោះគឺជាទេព្តាចិត្តល្អ ។ ប៉ុន្តែអាយ៉ោនមិនស្គាល់ថាជាអ្នកណាឡើយ ។

តាចាស់ទាំងពីរនិយាយថា: ម្នាលអ្នកក្លាហាន! អាណិតឲ្យយើងសុំអ្វីបន្តិចស៊ីផង, យើងគ្មានអ្វីសោះ សូម្បីតែបន្តិចបន្តួចក៏គ្មាន ។

អាយ៉ោនអ្នកចិត្តល្អឆ្លើយថា: បពិត្រលោកតាអើយ! ខ្ញុំបាទមានតែលុយប្រាំមួយសេននឹងនំប៉័ងមួយដុំទេ ខ្ញុំចែកជូនលោកតាពីរសេនម្នាក់នឹងនំប៉័ងកន្លះដុំម្នាក់ ។

តាចាស់ឆ្លើយថា: សូមអរគុណច្រើន ចៅក្លាហាន! ទេព្តានឹងសងអ្នកវិញ ច្រើនជាងវត្ថុដែលឯងបានឲ្យដល់យើងទៅទៀត ។ រួចតាចាស់ទាំងពីរក៏ធ្វើដំណើរហួសទៅ ។

ចំណែកអាយោនក៏ធ្វើដំណើរតទៅទៀតដែរ ប្រៀនតែម្នាក់ឯងស្ទើរបែកព្រួចជាក់ស្តួចផែនដី ។

ក្នុងវេលារៀបដើរឆ្លងកាត់ភ្នំ មានតាចាស់ពីរនាក់ទៀត គឺជាទេព្តាដដែល គ្រាន់តែផ្លាស់រូបភាព ហើយអាយោនមិនស្គាល់ជាតាចាស់ពីលើកមុនទេ ។

តាចាស់នេះសុំទៀតថា: ម្នាលចៅក្លាហាន ! ចូរឲ្យអីបន្តិចដល់យើងស៊ីផង ។

— មិនអីទេលោកតា ! ប៉ុន្តែនំប័ុងរបស់ខ្ញុំអស់ហើយ ព្រោះខ្ញុំបាទចែកជូនទៅលោកតាទាំងពីរអម្បាញ់មិញអស់ទៅ ខ្ញុំនៅសល់តែពីរសេនទេ ហ៎! សូមលោកតាអញ្ជើញយកមួយសេនម្នាក់ចុះ ។

តាចាស់ទទួលយក ហើយតាមួយនិយាយថា: នែតា ចូរស្តាប់ ! ចៅហាននេះគ្មាននៅសល់មួយសេនទុកខ្លួនសោះ ដូច្នេះត្រូវយើងឲ្យវត្ថុមួយដល់វា ដើម្បីកុំឲ្យស្លាប់ដោយការអត់ឃ្លាន ។

តាចាស់ទីពីរឆ្លើយថា: សូមបំណងរបស់ព្រះគុណសម្រេចចុះ ។

ហើយទេព្តានោះស្រែកហៅអាយោន ដែលដើរទៅឆ្ងាយហើយ ឲ្យត្រឡប់មកវិញ រួចនិយាយថា: នែចៅ ! ចូរឯងយកស្បោងនេះទៅចុះ ចៅអាចបញ្ចូលក្នុងស្បោងនេះតាមចិត្តចង់ នូវវត្ថុដែលចៅត្រូវការ ; ចៅគ្រាន់តែនិយាយថា : សូមព្រះអង្គជួយ កន្ទេលទេស្ពាក សូមឲ្យវត្ថុនេះចូលក្នុងស្បោងខ្ញុំ ។

អាយោននិយាយថា: "សូមអរព្រះគុណម្ចាស់ច្រើន," រួចទទួលយកស្បោងហើយបន្តដំណើរទៅទៀតធ្វើព្រងើយមិនចាំបាច់និយាយច្រើន ។

វាបានដល់តៀមលក់អាហារមួយ ។ វាឃ្លានបាយ ស្រមោចទាំពោះ ។ ប៉ុន្តែស៊ីដូចម្តេច បើគ្មានស្បៀង គ្មានសោហ៊ុយ ។ វាក្រឡេកទៅឯពិតានទីងបង្អួចភោជនដ្ឋាន វាឃើញសាច់ក្រកនិងនំបុងព្យួរនៅរណាង វាឃ្លានស្ទើរស្រក់ទឹកមាត់... ។ ខណៈនោះ វាក្រឡេកមើលក្នុងស្បោងហើយស្រែកថា: សូមព្រះអង្គជួយ កន្ទេលទេស្អាត, ខ្ញុំបាទត្រូវការនំបុងពីរនិងសាច់ក្រកមួយគូចូលក្នុងស្បោងខ្ញុំ ។

អាយោនភ្ញាក់ព្រើត ដោយឃើញនំបុងពីរនិងសាច់ក្រកមួយគូលោតចូលក្នុងស្បោងរបស់វា ។ វានៅអង្គុយក្បែរម៉ាស៊ីនទឹក រួចតាំងចាប់បរិភោគអាហារ វាស៊ីឃ្នុមៗ យកពេញៗមាត់ ហាក់ដូចជាខ្លាចនរណាមកនឹងដណ្តើមស៊ី ។ រួចវាដើរទៅទៀត ពេញដោយសេចក្តីក្លាហានជាថ្មី ហើយនិយាយដដែលៗថា: អញឈប់ខ្លាចនរណាទាំងអស់! អញឈប់ខ្លាចនរណាទាំងអស់! ។

អ្នកមានមុខម្នាក់ក្នុងភូមិនោះ បានឮអំនួតរបស់វាដូច្នោះ ក៏និយាយថា: បើអ្នកឯងមិនខ្លាចនរណាទាំងអស់ ចូរឈប់សិន គេនឹងនាំអ្នកទៅក្នុងផ្ទះមួយយ៉ាងល្អ ហើយឲ្យអ្នកអាស្រ័យនៅក្នុងទីនោះ រហូតអស់មួយជីវិត ។

— អើ! ដូចម្តេចក៏ដោយ ខ្ញុំឥតខ្លាចទាំងអស់ ។

គេនាំក៏ទៅក្នុងផ្ទះនោះដោយនឹកស្មានថា: ក៏មុខជានឹងស្លាប់មិនខាន ព្រោះគ្រប់មនុស្សទាំងអស់ ដែលត្រូវការទៅដេកល្បងមើលក្នុងផ្ទះនោះ តែងតែប្រទះនឹងសេចក្ដីស្លាប់ពុំខាន ។

អាយោននិយាយថា: សូមលោកឲ្យក្អមមួយ ដាក់មេរ័យពេញមកផង, ខ្ញុំយកទៅដាំផឹក គ្រាន់បានជាគ្នា ។

លុះនៅតែម្នាក់ឯងក្នុងផ្ទះ អាយោន ដាំមេរ័យផឹក ច្រៀងរឡូរឡា ។ មិនយូរប៉ុន្មាន ក៏ឮសូរដូចជាសំឡេងមួយស្អកៗ ខ្សាវៗ ដូចសំឡេងទាឈ្មោល ស្រែកពីលើស្កាកមក (សំឡេងនោះបើឮហើយ ធ្វើឲ្យព្រឺក្បាលប៉ុនកញ្ឆើ ស្មើនឹងសន្ទូប់) ពោលពាក្យដដែលៗថា: អាហ៎ អញធ្លាក់! អាហ៎ អញធ្លាក់! ។ អាយោនធ្វើព្រងើយ ។

រួចតមកអាយោននិយាយឥតងាកក្រោយ ដោយសំដីធម្មតាថា: អញឬដែលត្រូវធ្លាក់? គឺឯងទេតើ ។

បន្ទាប់ពីនោះភ្លាម ក្បាលមនុស្សមួយរមៀលចុះមកតាមបំពង់ផ្សែង ហើយមកតាំងនៅឆ្ដុបក្បែរអាយោន ដែលកំពុងតែកាន់ក្អមមេរ័យនៅដៃ ។

អាយោនស្រែកថា: នែរុ! ថយឲ្យឆ្ងាយបន្តិចទៅ, អីឯងចង់បំបែកក្អមមេរ័យអញ? ។ ប៉ុន្តែក្បាលនោះទៅស្ងៀម ៗ ក្នុងពេលជាមួយ, គេឮសូរមួយថ្មីទៀត ស្រែកថា: អាហ៎ អញធ្លាក់! អាហ៎ អញធ្លាក់ឥឡូវ! ។.

អាយោនកាន់តែភ្លមមេរ៉យ ហើយឆ្លើយថា: យី តាមចិត្ត! ធ្លាក់មកចុះ! ឯងទេតើ មិនគឺអញឯណា ។ អាយោនថាសឹងមិនផុតពីមាត់ ស្រាប់តែក៏ឃើញតួខ្លួនមនុស្សព្រមទាំងដៃជើង រមៀលធ្លាក់មកតាមបំពង់ផ្សែង ហើយលោតទៅភ្ជាប់នឹងក្បាល កើតបានជារូបមនុស្សម្នាក់ មានជើងដូចសេះ រួចស្ទុះទៅស្រគ្រប់អាយោនៗ មុនដំបូងភ័យដែរ តែលោនឹកតាន់ ក៏ស្រែកថា: ឱ! សូមព្រះអង្គជួយ កន្ទ្រីងនេះទទេស្អាត សូមបិសាចចូលក្នុងស្បោងអញមក ។

មួយរំពេចនោះ តើអ្នកជឿឬទេ? ខ្មោចបិសាចចូលទាំងបង្ខំទៅក្នុងស្បោង ហើយអាយោនចាប់បោកវិញ ស្អើរសំប៉ែតដូចត្រីយូហឺ ។

— អាយោនៗអាណិតអញ! អញសូមទោស! អញលែងហ៊ានមកជាន់ទីនេះអស់មួយជីវិតហើយ ។

— យើគ្មានទោសពៃរ៍អ្វីទេ ។

— អ្នកហាវហាន! សូមទោសៗ, ខ្ញុំជូនមាសដល់លោកពីរកញ្ចើ ។

— មាសនៅឯណា?

— មាសនៅក្នុងពាងខាងក្រោយផ្ទះ ។

វេលានោះ មាន់រងាវទឹកជោរពាក់កណ្ដាលអធ្រាត្រ, បិសាចប្រែតព្រមទាំងបរិវារទាំងឡាយ រត់បាត់អស់ ។ អាយោនបានជាម្ចាស់ប្រាក់ នឹងម្ចាស់ផ្ទះ ។ ក៏អាស្រ័យនៅក្នុងគេហស្ថាននោះប្រកបដោយ

សេចក្ដីសុខអស់កាលជាយូរ ៗ ប៉ុន្តែ គេតែងនិយាយជាហូរហែអំពីកិច្ចជំអស្ចារ្យរបស់វា ៗ រឿងនេះមិនបាត់ស្ងាត់ ឮល្បីឆ្ងាយទៅៗ ទាល់តែ មានមួយថ្ងៃ មានបទបញ្ជាមួយ បង្គាប់ឲ្យវាត្រឡប់ចូលបន្ទាយចាស់វាវិញ យ៉ាងឆាប់ៗ ដ្បិតបន្ទាយនោះ ត្រឡប់ក្លាយទៅជាកន្លែងបិសាចនៅ គ្មាននរណាអាចចូលជិតបាន ។

អាយោនទទឹករំពឹងថា: តើនឹងចេញទៅដូចម្ដេចកើត? តើអ្នកណានៅថែរក្សាផ្ទះឲ្យអញ ? ។ ពួកមេក្លូមិវាំងឡាយជឹងហើយប្រាប់ថា: សូមលោកកុំបារម្ភ ! យើងធានាមើលរក្សាជូន ។

វាក៏ទៅកាន់បន្ទាយនោះ ដែលប្រែកបិសាចបណ្ដេញទាហានរត់ចេញគ្មានសល់ម្នាក់ ។

អាយោនស្ថិតនៅក្នុងទីនោះផ្ងើព្រងើយ ហើយដេកដូចជាទីកន្លែងរបស់វា ។ ប៉ុន្តែ វាដេកលក់ឬទេ? ថាទេ ។ បិសាចច្រើនដូចជាសៅក្នុងចំការ មកបោមពេមវាយដំប្រចាក់នូវអាយោន ហើយស្រែកប្រាប់ថា: អាឯងកុំមកទៀត អាឯងកុំមកទៀត ។

អាយោនមុនជម្លងភ្ញាក់ឡើងលោករត់ចេញ លុះទីបំផុតទើបទឹកដល់ស្បាង:

— សូមព្រះអង្គជួយ កន្លែងទទេស្អាត, សូមឲ្យបិសាចទាំងអស់ចូលក្នុងស្បោងខ្ញុំ ។

ស្រាប់តែបិសាចទាំងនោះ ចូលញ៉ុកក្នុងស្បោង ៗ អាយោនគិតតែពីជាន់ដាក់សំពង ទាល់តែអមនុស្ស ស្រែកអង្វរលន់តួស្បថស្បែ ថាឈប់មកក្នុងទីនេះទៀតហើយ ៗ

ទុកាសនោះ . គ្រាន់តែអាយោនបង្ហើបមាត់ស្បោង អមនុស្សរត់ចេញប្រសេចប្រសាចលឿនដូចព្រួញ ទៅសូមជ្រកទីងស្ដេចព្រាយមួយឈ្មោះ បេស៊ីបុត្រ ៗ ចំណែកអាយោនកំពុងតែរៀបរបទីងសំពក ខ្ទមម្ដងទៀត ស្រាប់តែបេស៊ីបុត្រឯងមកដល់ភ្លាមហើយស្រែកសន្ធាប់ថាៈ ឪ អាចោរចៅស្រៃ! អាឯងមកក្នុងទីនេះធ្វើអ្វី? អាឯងមិនដឹងថា បន្ទាយនេះជាទីសំណាក់របស់យើងទេឬ? ៗ

- អញមិនដឹងថារបស់អាណាទាំងអស់ ៗ

- មិនដឹង! អើ អាឯងចាំមើលគង់ដឹង ៗ

បេស៊ីបុត្រចាប់ដំបងមួយយ៉ាងធំគ្រវីសំពងបំក្បាលអាយោនៗ ងើបឡើងដកដង្ហើមបានស្រួលភ្លាមកាលណាក៏តាំងស្រែកថាៈ សូមព្រះអង្គជួយ! កន្ទួងទទេស្អាត សូមឲ្យបេស៊ីបុត្រចូលក្នុងស្បោង ៗ

ស្រាប់តែបេស៊ីបុត្រវិលខ្លួនចូលឬកក្នុងស្បោង អាយោនចាប់សំពងគ្មានមើលមោង ព័ព័យទាល់តែឈឺដៃ ៗ បេស៊ីបុត្រ ស្ដេចព្រាយស្រែកអង្វរសូមទោសថាៈ អាយោន! អញសុំទោស, អញទុកបន្ទាយនេះទីងរបស់របរទាំងប៉ុន្មានខាងក្នុង ឲ្យអាឯងទាំងអស់ ៗ

– អាឯងស្បថថាឈប់មកទៀត ទើបអញព្រម, ឮឬទេ?

– អញឮហើយ អញនឹងឈប់មកទៀតហើយ ។

– អើ បើដូច្នេះ ទៅចុះ ។

រួចបេស៊ីបុត្រ ស្ទុះហោះរត់យ៉ាងលឿនៗ ជាងពេលដែលវាមកទៅទៀត ។ គ្រានោះ អាយោនអញ្ជើញអស់លោកឧត្ដមសេនីយ៍ និងពួកទាហានទាំងឡាយឲ្យត្រឡប់ចូលមកវិញ ។ ប៉ុន្តែពួកជនអស់នោះនៅតែមិនទាន់ជឿស៊ប់អស់ពីពោះ ។ ហើយចាប់ពីពេលនោះមក គេនាំគ្នាដេកជាសុខសប្បាយ មិនដែលមានខ្មោចបិសាចអ្វីមកយាយីទៀតឡើយ សូម្បីតែខ្មោចសង្កត់ក៏គ្មានផង ។ ចំណែកជនជាសប្បុរសទាំងឡាយ តែងនឹកឧបការគុណនៃអាយោនមិនភ្លេច ។

ខាងក្រោយការរៀបចំផ្ទះ ដែលបានពីព្រាយបិសាចនឹងបន្ទាយឲ្យបានស្រួលអស់អំឡុងប៉ុន្មានថ្ងៃហើយ អាយោនវិលទៅកាន់ផ្ទះកំណើតរបស់អាត្មា គឺផ្ទះដែលវាបានចាកចោលដើម្បីទៅធ្វើទាហាន ។ កំពុងដើរ, វាបានជួបតាចាស់ដែលបានឲ្យស្បោងដល់វា ហើយនិយាយប្រាប់ថា: នែចៅ! ចូរឯងប្រុងប្រយ័ត្ន នឹងសំដីដែលតា នឹងនិយាយប្រាប់ឯងឥឡូវ... ។

– មានការណ៍អ្វីតា? ។

– កាលណាឯងត្រឡប់ដល់ផ្ទះកំណើតហើយ ចូររៀបចំខ្លួនប្រាណរក្សាសីលធ្វើបុណ្យឲ្យទាន តាំងចិត្តឲ្យល្អ ហើយធ្វើម្ហូបទុកសម្រាប់

ខ្ញុំនឹង ដ្បិតមិនយូរប៉ុន្មានទេ មច្ចុនឹងមកយកអ្នកឯងហើយ ; ពេលឯងដល់ហើយ ខាងក្រោយមរណកាល ឯងនឹងទៅកើតឯស្ថានសួគ៌ ។

អាយោនស្លុតបទៅវិញ ដោយវាចាមិនពីរោះថា : តាឯងជាអ្វី បានជាហ៊ានមកនិយាយរឿងអប្រិយដូច្នេះដល់ខ្ញុំ? ។

— នែអាយោន ! អញជាព្រះឥន្ទ្រ ; បានជាអញឲ្យ ស្បៀងនេះដល់ឯង ព្រោះឯងចិត្តល្អ ។

— អីពិតមែន? ទ្រព្រះគុណអើយ ! សូមព្រះគុណអត់ទោសដល់ខ្ញុំៗ មិនស្គាល់ព្រះគុណជាអ្វីឡើយ ។

អាយោនលុតជង្គង់ ហើយនិយាយអង្វរទាំងទឹកភ្នែករហាមថា: បពិត្រព្រះគុណម្ចាស់ ! បើអាយុខ្ញុំម្ចាស់អស់ហើយ សូមមេត្តាបញ្ជូនមច្ចុរាជមកបង្ហាញខ្ញុំឲ្យចេះធ្វើម្ហូបសិន ដ្បិតខ្ញុំម្ចាស់រស់តែធ្វើទាហាននឹងធ្វើការដេញខ្មោចបិសាច ខ្ញុំមិនចេះធ្វើម្ហូបទេ ខ្ញុំមិនដែលទាំងស្គាល់យ៉ាងដូចម្តេច ម្ហូបនោះផង ។

— អើ មិនអីទេ បាន ។

លុះអាយោនបានទៅដល់ទីលំនៅ មច្ចុរាជក៏មកភ្លាម ។

— នែ ស្តេចមច្ចុ ចូរបង្ហាញខ្ញុំធ្វើម្ហូបបន្តិច ។

— ដូចម្តេច? អាតើ អីចឹងក៏មិនចេះធ្វើដែរ? ហ៎ ! ចាំមើល !

មច្ចុតាំងបង្ហាញឲ្យអាយោនរើសយកគ្រឿងល្អៗ និងត្រូវផ្គុំគ្នាបែបយ៉ាងណា ។ អាយោនចេះតែធ្វើតាមមច្ចុរាជកក់ខ្ទះត្រង់ណា រួចប្រាប់ថា:

បពិត្រលោកមច្ចុរាជ ! សូមលោកមេត្តា ចូលក្នុងឫស្សីជាដំបូង ហើយពិនិត្យមើល តើជាល្អ ឬ មិនល្អ ។

មច្ចុចូលក្នុងឫស្សីហើយនិយាយថា: ឫស្សីយើងល្អណាស់អាយោន !

– អីគ្មានរន្ធតូចមួយសោះ? គ្មានពន្លឺថ្ងៃចាំងចូលបន្តិចបន្តួចទេឬ?

– គ្មានទេ ងឹតស្លុង ។

គ្រាន់តែមច្ចុថា សឹងមិនទាន់ផុតពីមាត់ អាយោនយកគម្របមកដាក់បិទពីលើឫស្សី បោះភ្ជាប់នឹងដែកគោលយ៉ាងមាំ ហើយស្រែកប្រាប់ថា: អាឯងអាចចេញពីឫស្សីនេះបាន លុះត្រាតែឪពុកអញរស់ឡើងវិញ ហើយលុះត្រាតែអញព្រមបើកឲ្យចេញផង ។ រួចវាលើកឫស្សីយកទៅបោះចោលក្នុងទឹកស្ទឹង ។

អាយោនទាហានចាស់ ចេះតែនៅរស់តទៅ . . . ហើយវាភ្លេចទាំងថ្ងៃ ខែ ឆ្នាំ មិនដឹងជាវាកើតពីកាលបរិច្ឆេទណាឡើយ ។ អើ វាសម្លាប់មច្ចុបាន ពិតមែន? ។ ម្ល៉ោះហើយអំពើទុច្ចរិតចំរើនឡើងពាសពេញក្នុងលោក ដ្បិតឈប់មានមច្ចុរាជមកផ្តាច់ផ្តិលជីវិតសត្វទាំងឡាយ ។ ដោយការក្រស្លាប់ មិនដឹងយ៉ាងដូចម្តេចហៅថាស្លាប់ លោកិយជនតាំងចាប់ហែកគ្នាស៊ីទៅវិញទៅមកដូចតិរច្ឆាន ។

ជាទីបំផុត ខាងក្រោយការរស់នៅយូរពេក អាយោនក៏ឡើងទៅ

ស្ថានសួគ៌តាមបទបញ្ជានៃព្រះឥន្ទ្រ ។ លុះបានទៅដល់ទ្វារស្ថានសួគ៌ ក៏ឃើញទ្វារបិទជិត ក៏ចង់បើកទ្វារ តែពួកទេព្ដាស្ទុះមកឃាត់ ។

អាយោនរកធ្វើអ្វីមិនកើត ក៏ស្រែកថា: ឱព្រះគុណ ! សូមព្រះអង្គជួយ កន្លែងទទេស្អាត សូមឲ្យពួកទេព្ដា ចូលក្នុងស្បោងខ្ញុំ ។

ពួកទេវតាទាំងប៉ុន្មានទាំងធំទាំងតូច ចូលសុកប្រញាក់ក្នុងស្បោង, អាយោនលើកស្បោងស្ពាយដើរទៅរកព្រះឥន្ទ្រ ហើយនិយាយរឿងរ៉ាវហូរហែទូលព្រះឥន្ទ្រថា: បពិត្រព្រះគុណធ្ងន់ម្ចាស់ថ្លៃ ! ឥឡូវនេះខ្ញុំម្ចាស់មកស្ថានសួគ៌ តាមសេចក្ដីបង្គាប់របស់ព្រះអង្គ តែទេវតាទាំងឡាយ មិនចង់ឲ្យទូលព្រះបង្គំចូលមករកព្រះគុណ ; ខ្ញុំម្ចាស់ខំតវ៉ាដោយពាក្យសព្វគ្រប់ តែមិនសម្រេច ហើយខ្ញុំម្ចាស់ប្រមូលដាក់ក្នុងស្បោងយកមក ។

ចំណែកព្រះឥន្ទ្រ ទ្រង់ដោះលែងទាំងទេព្ដាទាំងមច្ចុរាជ ។ តមកវត្តុទាំងនោះត្រឡប់ចាប់ធ្វើការដូចដើម តាមមុខក្រសួងរៀងខ្លួនក្នុងលោក, មច្ចុក៏ចាប់បំពេញកិច្ចរបស់អាត្មា តាមការណ៍ដែលគួរធ្វើ ។ ព្រះឥន្ទ្រឲ្យមាតលីទេវបុត្រនាំយកអាយោនមកកាន់ផែនដីវិញ ។

ចប់

## ការបណ្ដុះងំស្ស័យ

## ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

រឿងនេះជាគុណធម៌ ដែលជាលក្ខណៈរបស់ចិត្តឧបអរសោទរ ៗ បើលោក-អ្នកអប់រំបានហើយ លោក-អ្នករមែងមានចិត្តឧបអរសោទរត្រជាក់ត្រជំនឹងទូលំទូលាយ ប្រាថ្នាសេចក្តីសាមគ្គីព្រមព្រៀងគ្នារលាយសាប់មួយ ចេះទទឹង ចេះបណ្ដោយ មិនទន់ពេក មិនរឹងពេក មិនក្ដៅពេកទាល់តែឆេះ មិនត្រជាក់ពេកទាល់តែកក ចេះអើពើជួយសង្គ្រោះគ្នា ជាអ្នកផុតចាកទោស គឺល្ងង់ខ្លៅគួរខ្ពើម ចេះគួរស្អប់, និងសម្បូរទៅដោយគុណ គឺបើល្ងង់ គួរឲ្យអាណិតស្រឡាញ់ ចេះគួររាប់អាន, ជាមនុស្សដែលអ្នកដទៃគ្រាន់តែឃើញ ឬគ្រាន់តែនឹកឃើញ កើតសេចក្តីស្រឡាញ់គោរពរាប់អាន និងបានសេចក្តីសោមនស្សពេញចិត្ត ចង់ផ្អែកកោនការពារភ័យ ៗ ពិតមែន របស់ដែលដូចគ្នា រមែងប៉ះគ្នាបាន ។ មាសរមែងប៉ះនឹងមាស, ដែករមែងប៉ះនឹងដែក, ទុក្ខរមែងប៉ះនឹងទុក្ខ, សុខរមែងប៉ះនឹងសុខ, អ្នករាប់អានគេ រមែងប៉ះនឹងការរាប់អានតប, អ្នកបូជាគេ រមែងប៉ះនឹងការបូជាតប និងអ្នកគោរពគេ រមែងប៉ះនឹងការគោរពតបវិញ ៗ

៣.— ចិត្តដែលស្គាល់ចិត្តថ្លើមគេឯង — អ្នកដែលយល់ចិត្តយល់ថ្លើមគេឯងនោះ រមែងចេះប្រៀបធៀបសេចក្ដីដឹងរបស់អ្នកដទៃនឹងសេចក្ដីដឹងរបស់ខ្លួន ដូចយ៉ាងចេះស្គាល់ការនឿយហត់ ស្គាល់ការសុខសម្រាន្ត ស្គាល់ការវិតក្ក ស្គាល់អារម្មណ៍ល្អ ឬអាក្រក់ ស្គាល់ខឹងឬជា ស្គាល់ការខុសបំណងឬត្រូវបំណងជាដើម គឺឃើញថាបំណងរបស់គេមានដំទៃ្យដូចបំណងរបស់ខ្លួនដែរ ឃើញថាគេទាំងអស់ក៏ជាមនុស្សដូចគ្នា ការមានបំណងក្នុងផ្លូវត្រូវរបស់គេ រមែងមានសិទ្ធិប៉ុនគ្នានឹងបំណងក្នុងផ្លូវត្រូវរបស់ខ្លួនដែរ សូម្បីកាលកើតសេចក្ដីគិតឃើញឡើង ក៏គាត់យកដំណឹងរបស់គេឲ្យដូចជាដំណឹងរបស់ខ្លួនដែរ ប្រតិបត្តិចំពោះអ្នកដទៃដូចជាប្រតិបត្តិចំពោះខ្លួនដែរ យកចិត្តខ្លួនទៅប្រៀបនឹងចិត្តគេ យកចិត្តគេមកប្រៀបនឹងចិត្តខ្លួន ជួយត្រេកអរក្នុងកាលដែលឃើញគេត្រេកអរ ជួយសុតស្ងប់ក្នុងកាលដែលឃើញគេបានទុក្ខ គឺធ្វើរឿងដែលមកជួបប្រសព្វចំពោះអ្នកដទៃ ឲ្យហាក់ដូចជារឿងនោះមកជួបប្រសព្វចំពោះខ្លួនដែរ ។

អ្នកប្រាជ្ញខាងចិត្តសាស្ត្រនឹងវិទ្យាសាស្ត្រ បានអនុម័តព្រមគ្នាថា “ លលាដ៍(១) សីសៈរបស់មនុស្សយើងមានលក្ខណៈដូចគ្រឿងផ្សាយនឹងគ្រឿងទទួលរលកធាតុនៃវិទ្យុ ។ បើមនុស្ស ១ បញ្ជូនមិត្តចិត្តទៅឲ្យ, មនុស្សម្នាក់ទៀតក៏បញ្ជូនមិត្តចិត្តតបមកវិញដែរ ” ។ ដូច្នេះ អ្នកដែល

១ ត្រូវអានថា លលា ។

បានយល់ចិត្តយល់ថ្លើមអ្នកដទៃ កាលបើធ្វើនិយាយ ឬ គិតអ្វីតែងបញ្ជូនចិត្តទៅត្រួតមើលចិត្តរបស់អ្នកដទៃមុនជានិច្ចថា " គេមានគំនិតនឹងចំណង់យ៉ាងណា ? " ។ ការពិនិត្យមើលបែបនេះ លោកប្រៀបដូចវិទ្យុ ព្រោះស្ទុះចេញអំពីចិត្តមួយទៅកាន់ចិត្តមួយ អំពីចិត្តអ្នកធំដែលប្រកបដោយយសសក្តិសម្បត្តិទៅកាន់ចិត្តរបស់អ្នកតូច ដែលគ្មានយសសក្តិសម្បត្តិបាន, សប្បាយជាមួយអ្នកដែលសប្បាយ សត់សប់ជាមួយអ្នកដែលសត់សប់ ។ មនុស្សដែលធ្វើបែបនេះបាន ចាត់ថាជាអ្នកមានប្រក្រតីយល់ចិត្តយល់ថ្លើមគេឯង ។ សូម្បីមនុស្សដែលអន់ថាង មនុស្សដែលតាំងនៅក្នុងការឃុំគ្រង នឹងមនុស្សស្មើគ្នា ដរាបដល់សត្វដែលចិញ្ចឹម ក៏បានទទួលការយល់ចិត្តយល់ថ្លើម អំពីមនុស្សបែបនេះផងដែរ ។ " ការមានអាយុវែងហើយអាចជាទីរឭកឃើញនៃគ្នានឹងគ្នាបានយូរអង្វែងនោះ គឺការយល់ចិត្តយល់ថ្លើមគ្នាទៅវិញទៅមក " ។ នេះជាឧត្តមគតិ បូរបាំទុកបុះ ។

៤.— ចិត្តនឹងធួន — គឺចិត្តខ្ជាប់ខ្ជួន ។ អ្នកមានចិត្តខ្ជាប់ខ្ជួននឹងខ្លួនរមែងជាមនុស្សនឹងធឹង រឹងប៉ឹងក្នុងហេតុក្នុងផល មិនមានចិត្តស្រាលជឿងាយៗ មិនមានចិត្តប្រែប្រួលរវើរវាយរាយមាយសាវ៉ា ឬ រឡេះរឡះមិនអណ្តែតអណ្តូង មានសតិជានាយឃុំគ្រងចិត្តរបស់ខ្លួន ចេះបង្គាប់បញ្ជាចិត្តខ្លួនឲ្យតាំងនៅក្រោមបង្គាប់ខ្លួន មិនទោរទន់ទៅតាមគេងាយៗ មិនបណ្តោយខ្លួនឲ្យដូចជាសំឡីឬស្មៅ អណ្តែតតាមខ្យល់តាមទឹក បង្ខាំងខ្លួនឲ្យជ្រកនៅក្រោមម្លប់នៃសេចក្តីល្អ សូម្បីមានភ្នែកមានត្រចៀកអាចមើល

រូបគ្រប់យ៉ាងឃើញដោយភ្នែក ស្តាប់សំឡេងគ្រប់បែបបានដោយត្រចៀកក៏ដោយ ក៏ធ្វើជាខ្វាក់ជាថ្លង់ មិនរំភើបញាប់ញ័រក្នុងវត្ថុដែលបានឃើញបានឮនោះ មិនប្រាថ្នាវត្ថុដែលមិនត្រូវបាន មិនសោកស្តាយវត្ថុដែលវិនាសទៅ សូម្បីបានសម្បត្តិដែលគួររីករាយ ក៏មិនស្រើងរង្វើង មានកំឡាំងចិត្តអង់អាចល្មមធ្វើឲ្យដួងបញ្ញាភ្លឺថ្លា ឃើញអត្ថឃើញធម៌ តាមហេតុតាមផល នឹងវិនិច្ឆ័យបានត្រឹមត្រូវ ៗ

លោក – អ្នកទាំងឡាយ ចូរមានចិត្តនឹងនួន ស្មោះត្រង់ចំពោះខ្លួនឯង ៗ កុំភូតកុហកលួងនឹងមើលងាយចំពោះខ្លួន ៗ ត្រូវប្រតិបត្តិតាមសេចក្តីខុសនឹងត្រូវដែលខ្លួនបានដឹង គឺបើដឹងថាអ្វីខុស កុំប្រកាន់យក ចូរផ្ចញ់ផ្ចាល់ខ្លួនឯងឲ្យឃើញត្រូវ បើដឹងថាអ្វីអាក្រក់ កុំកន្លងល្មើសធ្វើទៅទាំងបំពាន ៗ បើមិនទាន់បានពិចារណាឲ្យឃើញហេតុផលចំពោះខ្លួនទេ កុំអាលជឿតែងាយៗ ៗ ចូររឹងប៉ឹងក្នុងហេតុផល កាលជួបប្រទះនឹងហេតុការណ៍ដែលគួររន្ធត់ គួរខ្លាច គួរតក់ស្លុត ក៏កុំរន្ធត់ កុំខ្លាច កុំញាប់ញ័រ ៗ ចូរមានចិត្តសប្បាយរីករាយក្នុងកាលដែលប្រទះនឹងទុក្ខ ៗ ចូរមានចិត្តខ្ជាប់ខ្ជួនក្នុងអារម្មណ៍ដែលខ្លួនប្រាថ្នា ៗ កុំរវើរវាយរាយមាយអណ្តែតអណ្តូងទៅក្នុងអារម្មណ៍ដទៃ ៗ ចូរធ្វើកិច្ចដែលខ្លួនចាប់ធ្វើហើយឲ្យសម្រេចទៅកុំបង្អង់ ៗ ព្រោះថាសត្វវត្ថុក្នុងលោកនេះ បើលោកអ្នកជាមនុស្សចិត្តស្រាលរវើរវាយរាយមាយសាព៉ាហើយ សូម្បីវត្ថុនោះ

ត្រឹមតែ ១ ចំណែក ក៏នឹងក្លាយជាយល់សប្តិដល់ទៅ ១០ ចំណែក ឬ បើ យ៉ាងពិតណាស់ ក៏ត្រឹមតែ ១ ចំណែកប៉ុណ្ណោះ ៩ ចំណែកទៀត ទៅជាយល់សប្តិ ។ លុះតែលោកអ្នកមានចិត្តនឹងធឹង ទើបបានទៅជាសេចក្តីពិតទាំង ១០ ចំណែក ឬបើយ៉ាងអន់ណាស់ ក៏ជាយល់សប្តិត្រឹមតែ ១ ចំណែកប៉ុណ្ណោះ ៦ ៩ ចំណែកទៀត ជារបស់ប្រាកដប្រជា ។

ចិត្តនឹងធឹងនោះ គឺចិត្តនឹងធឹងកង់វត្ថុដែលគាប់ចិត្ត ឬកង់វត្ថុដែលមិនគាប់ចិត្ត ។ ឯវិធីដែលនឹងប្រតិបត្តិចំពោះវត្ថុគាប់ចិត្តមាន ៣ ប្រការ គឺ:

ក ) កាលបើលោក-អ្នកស្វែងរក ក៏កុំស្វែងរកឲ្យខុសធម៌ ចូរស្វែងរកតែដោយត្រូវធម៌ ។

ខ ) កាលបើនឹងប្រើការសង្គ្រោះ ក៏កុំសង្គ្រោះដោយសេចក្តីរង្វើងភ្លើតភ្លើន ។

គ ) កាលបើនឹងចាកចេញ ក៏កុំចាកចេញដោយទោមនស្ស ។

សូម្បីវិធីដែលគប្បីប្រតិបត្តិចំពោះវត្ថុដែលមិនគាប់ចិត្តនោះ ក៏មាន ៣ ដែរ គឺ:

ក ) កាលបើអន្តរាយមិនទាន់មកដល់ ចូរការពារខ្លួនដោយសេចក្តីមិនប្រមាទទុកឲ្យហើយជាមុន ។

ខ ) បើមកដល់ហើយ ចូរកុំសៅសោក ។

គ ) បើអន្តរាយនោះ វិនាសបាត់ទៅវិញហើយ ក៏កុំកំរើបចិត្តរីករាយសប្បាយពេក ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ១១

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខណៈនោះ មានបំរើសេះមកប្រាប់លីឈុយថា គៀវបេលើកទាហានមក ១ កងពីខាងទិសឯលិច ហើយស្រែកប្រកាសថា នឹងមកឃាត់ហាមលោកមិនឲ្យច្បាំងគ្នានឹងគុយគី បើខាងណាមិនស្តាប់ គៀវបេនឹងធ្វើសង្គ្រាមតនឹងអ្នកនោះ ៗ លីឈុយគិតថា ទាហានយើងក៏នៅស្រាលស្តើងណាស់ហើយ, ដែលនឹងធ្វើសឹកតទៅនឹងគុយគីនោះឃើញទុញទាល់ណាស់ គៀវបេមកឃាត់ហាមនោះក៏សមប្រកបនឹងគំនិតយើងដែរ គួរតែយើងធ្វើមេត្រីទុកឲ្យគៀវបេឃើញថា យើងស្តាប់ពាក្យសំដី-គិតហើយក៏ចាត់ទាហានឲ្យទៅទទួលហើយផ្តាំឲ្យប្រាប់គៀវបេថា យើង

បានឮដំណឹងថាតៀវចេនឹងមកឃាត់មិនឲ្យច្បាំងគ្នានឹងគុយគីនោះ យើង
យល់មុខតៀវចេណាស់ បានជាព្រមស្ដាប់តាមពាក្យ ។

គុយគីបានដឹងដំណឹង ក៏ប្រើទាហានចេញទៅនិយាយនឹងតៀវចេថា
ដែលលោកលើកទាហានមកឃាត់ហាម មិនឲ្យច្បាំងគ្នានឹងលីឈុយនោះ
គុយគីព្រមស្ដាប់តាមពាក្យយាត់ហើយ ។ តៀវចេមានចិត្តត្រេកអរ
ណាស់ តាំងឲ្យបោះទ័ពឈប់ទ័ពនៅទីនោះ ហើយធ្វើសំបុត្រចូលទៅ
ក្រាបបង្គំទូលព្រះចៅហៀនតេថា ទូលព្រះបង្គំជាខ្ញុំតៀវចេបានមកឃាត់
ហាមលីឈុយគុយគីទាំងសងខាង បានព្រមសះសាជានឹងគ្នាលែងច្បាំង
គ្នាហើយ ទូលព្រះបង្គំជាខ្ញុំ សូមអញ្ជើញព្រះអង្គយាងទៅគង់នៅ
ស្រុកហងឡង ដែលជាមុខគយស្រុកតៀវហាន់ ។

ព្រះចៅហៀនតេមានព្រះទ័យសោមនស្សត្រាស់ថា សម័យតាំងគុ:
យើងក៏ចេញចាកស្រុកឡកអៀងមកនៅស្រុកតៀវហាន់, គ្រានេះរើមក
នៅស្រុកដែលតាំងគុ:សាងថ្មីទៀត ក៏មានតែទុក្ខបង្អៀតរកសេចក្ដីសុខ
គ្មាន ឥឡូវនេះតៀវចេបង់ឲ្យទៅនៅស្រុកហងឡងវិញ ប្រហែលនឹង
បាត់ទុក្ខ មានសេចក្ដីសុខ ព្រោះបុណ្យរបស់យើងទេដឹង" ទ្រង់ព្រះ
ចិន្តាហើយ ក៏តាំងឲ្យតៀវចេធ្វើជា "តៀវគីបុងគុន" ប្រែថា "នាយ
ទាហានធំ" ។ តៀវចេបានឡើងទីក៏មានសេចក្ដីត្រេកអរណាស់ ទើប
យាត់ចែងចំណីត្រីសាច់នឹងរបស់ត្រកាលនាំចូលទៅថ្វាយ ។ ព្រះចៅ
ហៀនតេក៏ទ្រង់ព្រះរាជទានឲ្យបាវព្រាវទាំងពួងដែលអត់ឃ្លាន ។

គុយគីដឹងដូច្នោះ ក៏បើកលែងនាហ្មឺនដែលត្រូវឃុំគុំគុកនោះ នាំយកទៅថ្វាយព្រះចៅហៀនតេ ។ បណ្ដានាហ្មឺនមុខមន្ត្រីខុំរាជការតូចធំក៏ប្រជុំគ្នា ចាត់ចែងទាហានទឹងគ្រឿងហែហមព្រមបរិបូណ៌ហើយ ក៏អញ្ជើញព្រះចៅហៀនតេនឹងព្រះអគ្គមហេសីស្រីព្រះស្នំ ឡើងគង់ព្រះរាជរថ លើកព្យុហៈយាត្រាកាត់ស្រុកស៊ុនឡុង ធ្ងង់ទៅដល់ស្ពានទេវទ្ទុប៉ាឡេង ទទួលព្រួសំឡេងស្រែកហៅកញ្ច្រៀវ ហើយលើកទាហានមកស្កាត់នៅលើស្ពាន នាយទាហានក៏ស្រែកសួរថា ដែលលើកមកនេះនឹងទៅណា? ។ អៀវគីបរសេះឡើងលើស្ពាន ហើយស្រែកតបថា ព្រះចៅហៀនតេស្ដេចយាងមក, ដែលលើកទាហានមកស្កាត់លើស្ពាននេះ ឈ្មោះអ្វី? ម្ដេចមិនក្រាបថ្វាយបង្គំ? ។ ទាហានឯក ២ នាក់ឆ្លើយតបថា គុយគីឲ្យយើងមករក្សាផ្លូវនេះ មិនឲ្យនរណាទៅជួយលីឈុយ, ដែលអ្នកថាព្រះចៅហៀនតេស្ដេចមក នោះចូរឲ្យយើងឃើញច្បាស់សិនយើងនឹងថ្វាយបង្គំហើយបើកផ្លូវឲ្យស្ដេចយាងទៅ ។ អៀវគីក៏ឲ្យទាហានស្រែកបង្ខំបរព្រះរាជរថនោះឡើងមកលើស្ពាន ព្រះចៅហៀនតេក៏ទ្រង់បើកព្រះមាលីចេញ ហើយត្រាស់ថាបរឲ្យធាប់ឡើងនឹងកាលផុតស្ពាន ។ ទាហានទាំងពួងឃើញជាក់ច្បាស់ក៏លុតជង្គង់ថ្វាយបង្គំទាំងអស់គ្នា រាថយពីលើស្ពានចេញទៅ ព្រះរាជរថក៏លឿនផុតស្ពាន ។

ខណៈនោះនាយទាហានទាំង ២ នាក់ ត្រឡប់ទៅប្រាប់គុយគីថា ព្រះចៅហៀនតេ- យាងទៅដល់ស្ពានទេវទ្ទុប៉ាឡេងហើយធ្លងហួសទៅ

ហើយ ៗ គុយគីព្រួដូច្នោះខឹងណាស់ថា "យើងស្ដាប់តែវចេតែមាត់ យើងនឹងឲ្យលើកទាហានទៅស្កាត់ចាប់ព្រះចៅហៀនគេ ឯទីក្រុងដែលតាំងគុះសានថ្មី, ហេតុអ្វីមិនធ្វើតាមបង្គាប់ ក៏ត្រឡប់ឲ្យស្ដេចយាងហួសទៅបាន" ថាហើយក៏ឲ្យយកនាយទាហានទាំង ២ នោះទៅសម្លាប់ចោល រួចលើកទ័ពតាមទៅ ៗ ព្រះចៅហៀនគេយាងទៅដល់ស្រុកប្វហ៊ុម ក៏បានព្រួសំឡេងទាហានហៅកញ្ជ្រៀវពីក្រោយថា នាហ្មឺនទាំងអស់គ្នា កុំអាលនាំយកស្ដេចទៅណា ឲ្យបង្អង់ឈប់សិន ៗ

ព្រះចៅហៀនគេព្រួដូច្នោះ ទ្រង់ព្រះកន្ទ្វង់សោកា ហើយត្រាស់ថា ផុតពីលីឈុយមកហើយគិតថានឹងធូរទូលាយសប្បាយចិត្តខ្លះ ថែមមកប្រទះនឹងទាហានកំងផ្លូវស្ពានទៀត ឥឡូវនេះមានគេតាមមកទៀត បៀតដល់ទីនេះនឹងភាសទៅខាងណា ចេញពីមាត់ខ្លាទៅចូលមាត់ក្រពើដូច្នេះ គ្រានេះនឹងគិតដូចម្ដេចទើបនឹងបានរួចភ័យ ៗ មន្ត្រីទាំងអស់មិនបានឆ្លើយថាដូចម្ដេច ៗ ឯទ័ពគុយគីក៏លើកមួយរំពេចចូលមកទៀត, ព្រះចៅហៀនគេរឹតតែទ្រង់ព្រះកន្ទ្វង់សោកានៅលើព្រះកជរថនោះ ៗ

ឯអៀវហាង ដែលរត់ពីលីឈុយទៅៗ នៅសំណាក់កុកង់កុំសាំសាន់ខាងទិសបស្ចិមនោះ លុះដឹងដំណឹងថា ព្រះចៅហៀនគេស្ដេចយាងទៅដល់ស្រុកហាងឡង់ ក៏តាំងតែក្ដុំសេនាទាហានលើកតាមស្ដេចទៅ ដើម្បីនឹងជួយការពារសេចក្ដីអន្តរាយ, លុះលើកទៅដល់ទល់នឹងក្បួនហៃដែល

ស្តេចព្រះរាជដំណើរ ក៏ពើបពះប្រទះនឹងកងទ័ពគុយគីលើកដេញតាមពីក្រោយ អៀវហង់ក៏លើកទាហានបណ្តោយចូលទៅស្ទាក់កងទ័ពគុយគីជាប់ ៗ ស៊ុយយ៉ុងសេនាគុយគីក្រឡេកឃើញកងទ័ពអៀវហង់លើកមកស្ទាក់ ក៏ញាក់សេះពារទាហានពានទៅពីមុខ ហើយស្រែកដេរអៀវហង់ជាពាក្យអាស្រូវកាសផ្សេងៗ ៗ អៀវហង់ខឹងណាស់ប្រើស៊ីឡុងសេនាឯកឲ្យកាន់ព្លូថៅធំដែកចេញទៅតយុទ្ធនឹងស៊ីឡុង បានតែមួយស្របក់ ស៊ីឡុងក៏កាប់ស៊ុយយ៉ុងធ្លាក់ពីលើសេះស្លាប់ ៗ អៀវហង់ក៏លើកកងទាហានបំពានចូលទៅ ប្រកាប់កងទ័ពគុយគីស្លាប់ដេរដាសពលទាហានរត់រាសចូលព្រៃ ហើយដេញតាមទៅចម្ងាយផ្លូវប្រហែល ២០០ សិន (៨ គ-ម៉) រួចអៀវហង់លើកត្រឡប់នាំកងទ័ពចូលទៅថ្វាយព្រះចៅហៀនតេ ៗ ទ្រង់មានព្រះតម្រាស់សាកសួរដោយរេះរាយហើយថា អៀវហង់លើកទាហានមកជួយយើងគ្រានេះ ជាគុណូបការៈដ៏ទម្ងន់ណាស់ យើងមិនភ្លេចគុណអ្នកតទៅទៀត ឯសេនារបស់អ្នកដែលបានសម្លាប់ស៊ុយយ៉ុងនោះ ឥឡូវនៅឯណា ? សុំឲ្យនាំខ្លួនមកបង្ហាញឲ្យយើងស្គាល់មុខ ៗ អៀវហង់ឲ្យហៅស៊ីឡុងចូលមកគាល់ ហើយអៀវហង់ក្រាបបង្គំទូលថា ស៊ីឡុងនេះជាពួកអ្នកស្រុកហោតាំង ៗ

ព្រះចៅហៀនតេទ្រង់មានព្រះតម្រាស់ថា អ្នកទាំង ២ នេះបានធ្វើសេចក្តីគាប់ប្រសើរលើខ្លួនយើងៗ សុំឲ្យអ្នកទាំងអស់គ្នានៅជាមួយនឹង

យើងតទៅចុះ ៗ លុះវេលាយប់អៀវហងឲ្យរៀបតាំងបន្ទាយពយដ៏រ៉ិញ ដើម្បីការពាររក្សាព្រះអង្គព្រះចៅហៀនតេ ៗ

ឯគុយគីដែលបែកទ័ពត្រឡប់ទៅនោះ ឃានបញ្ចុះបញ្ចូលប្រមូលសេនាទាហានច្រើនឡើងវិញ លុះព្រឹកឡើងក៏លើកជាក្បួនទ័ពត្រឡប់តាមទៅច្បាំងនឹងអៀវហងទៀត ៗ ស៊ីឡុងក៏ប្រុងប្រៀបរៀបទាហានជាក្បួនទ័ពស្រេច ដល់ឃើញទាហានគុយគីលើកទៅឡោមព័ទ្ធជុំវិញ ក៏បរសេះនឹងចេញទៅតទល់គ្នា ស្រាប់តែឃើញតាំងស៊ុនលើកយោធាពារទំលាយកងទ័ពគុយគី ពីទិសខាងកើតចូលមក កងទ័ពគុយគីបែកបាក់ខ្ចាត់ខ្ចាយរត់ប្រៀតជ្រែកជាចលាចល ៗ ស៊ីឡុងក៏បរពលចូលខ្ទប់ពីខាងលិចគេចបាក់កាប់សម្លាប់ ទាហានគុយគីវិនាសស្លាប់ជាច្រើន ៗ គុយគីបែកទ័ពលើកត្រឡប់ទៅវិញ មិនមានសេសសល់ឡើយ ៗ

តាំងស៊ុននោះមិញចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេ។ ទតយល់តាំងស៊ុន ទ្រង់ព្រះកន្សែងថ្ងៃសោកា ត្រាស់បរិហាររឿងរ៉ាវដែលព្រួយលំបាកឲ្យតាំងស៊ុនស្តាប់គ្រប់ប្រការ ៗ តាំងស៊ុនក្រាបទូលថាកុំឲ្យព្រះអង្គទ្រង់ព្រះវិតក្កតទៅទៀត ការក្រងាយទូលាយបង្អៀត សឹមទូលព្រះបង្គំជាខ្ញុំនឹងអៀវហង រង់ទទួលរក្សាការពារព្រះអង្គតទៅ ឯខ្មាំងអាសត្រូវទាំង ២ នាក់ ទូលព្រះបង្គំជាខ្ញុំនឹងសុំជាធុរៈកាប់សម្លាប់ចេញឲ្យបាន ដើម្បីនឹងឲ្យផែនដីជាសុខក្សេមក្សាន្តតទៅ ៗព្រះចៅហៀន

គេទ្រង់ត្រេកអរសោទរក្នុងព្រះទ័យណាស់ ត្រាស់ឲ្យលើកព្យុហៈទ័ពទៅទាំងយប់ទាំងថ្ងៃ ក៏បានទៅដល់ស្រុកហង់ឡូង ។

ឯគុយគីមានតែទ័ពទាមនស្ស ព្រោះចាញ់ទ័ពពីរគ្រា ទំប្រមូលពលយោធាដែលបាក់បែកនោះបានមកវិញខ្លះ ។ ខាងលីឈុយនោះលើកកងទ័ពតាមទៅទៀត ប្រាថ្នានឹងធ្វើអន្តរាយព្រះចៅហៀនតេឲ្យបាន, លុះទៅជួបនឹងគុយគី អ្នកទាំង ២ ក៏សះជានឹងគ្នាហើយប្រឹក្សាគ្នាថា តាំងស៊ុននឹងអៀវហង នាំយកព្រះចៅហៀនតេស្តេចទៅឯស្រុកហង់ឡូងដែលមានផ្លូវទៅលើក្រុងតៀវហាន់, បើស្តេចរហូតទៅនៅតាំងទ័ពខ្ជាប់ខ្ជួនក្នុងស្រុកតៀវហាន់ហើយ គង់នឹងមានសំបុត្រព្រះតម្រាស់ទៅដល់អាណាខេត្តក្រៅទាំងប៉ុន្មាន ឲ្យលើកពលទាហានមកធ្វើទុក្ខបុកម្នេញយើងទាំង ២ ជាប្រាកដ ។ លីឈុយតបថា ឥឡូវនេះតៀវចេតាំងទីរក្សាស្រុកតៀវហាន់ មានសេនាទាហានខ្លាំងពូកែច្រើនណាស់ យើងនឹងលើកទៅប៉ះក៏មិនបាន ត្រូវតែយើងទាំង ២ លើកតាមទៅឯស្រុកហង់ឡូងវិញ ដើម្បីនឹងចាប់យកព្រះចៅហៀនតេសម្លាប់ចេញ បើសម្លាប់បានហើយ ទ្រព្យសម្បត្តិទាំងប៉ុន្មានយើងត្រូវបែងចែកគ្នាពាក់កណ្តាលម្នាក់ ។ គុយគីបានស្តាប់ក៏ចាប់ចិត្តគិតអរណាស់ ព្រោះជាមនុស្សមានសេចក្តីលោភលន់ នាំលីឈុយលើកទ័ពទៅដល់ទីតំបន់ណា ឲ្យសេនាទាហានទន្ទ្រានរឹបរកគក្សាតយកទ្រព្យរបស់ អស់អាណាប្រជានុរាស្ត្រក្នុងទីនោះ ។

ចំណែកតាំងស៊ុនអៀវហង់នាំស្តេចទៅដល់តំបន់តាន់កាន់ ដឹងថា "លីឈុយ ទឹងគុយគី រួមគំនិតគិតលើកទ័ពតាមចាប់ព្រះចៅហៀនតេ" ក៏បញ្ជាប់ពួកកងទ័ពនៅទីនោះ ហើយប្រុងប្រៀបរៀបសេនាទាហានការពាររក្សាព្រះអង្គ ។

ឯលីឈុយទឹងគុយគីប្រឹក្សាគ្នាថា "ទាហានយើងលើកមកច្រើនជាងទាហានតាំងស៊ុនទឹងអៀវហង់ យើងទឹងលើកចូលទៅតតាំងច្បាំងដណ្តើមយកព្រះចៅហៀនតេប្រហែលបាន" លុះគិតព្រមគ្នាហើយក៏បែងកងទ័ពម្នាក់ពាក់កណ្តាលលើកចូលទៅជាបែកឆ្វេង-ស្តាំ ។ តាំង-ស៊ុនទឹងអៀវហង់ក៏រង់ទទួលតតាំងច្បាំងគ្នា លុះឃើញថាកំឡាំងទឹងតទល់ពុំឈ្នះ តាំងស៊ុនទឹងអៀវហង់ក៏លើកប្រាសរត់យកតែខ្លួន បោលអស់របស់ទ្រព្យទឹងគ្រឿងប្រដាប់ផ្សេង ៗ ហើយនាំយកព្រះចៅហៀនតេទឹងព្រះអគ្គមហេសីស្រីព្រះស្នំនៅអស់នាហ៊ឺនមុខមន្ត្រី ពារទំលាយកងទ័ពលីឈុយគុយគីចេញទៅទិសខាងជើង ។ លីឈុយគុយគីក៏លើកទាហានដេញចេញទៅ, ឯទ្រព្យរបស់ដែលសល់នៅ ពួកទាហានលីឈុយគុយគីជេញយកទៅទាំងអស់ យកទាំងទ្រព្យរបស់អាណាប្រជានុរាស្ត្រកងស្រុកហង់ឡូងថែមទៀត ។

(មានត)

## ព្រះរាជពង្សាវតារប្រទេសកម្ពុជា
## ភាគទី ២
## សម័យឆតរជំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

ការបេញក្រៅព្រះបរមរាជវាំង – តាមសេចក្តីកត់ហេតុរបស់ជាវតាកួន និយាយត្រូសថា: វេលាស្តេចចេញក្រៅព្រះបរមរាជវាំង រមែងមានក្បួនហែជាដពប, ក្បួនហែជាធម្មតា (មិនមែនក្បួនសឹក) មានរបៀបយ៉ាងនេះ:

ទី ១ – កងទាហានសេះ មានចំនួនច្រើន ហែនាំមុខបង្អស់ ។

ទី ២ – បន្ទាប់មក ក្រុមទង់ជ័យធំ និងក្រុមទង់ជ័យតូច ។

ទី ៣ – ក្រុមភ្លេងផ្សេងៗ ។

ទី ៤ – ក្រុមកុមារីក្នុងព្រះបរមរាជវាំង មានចំនួនពី ៣០០ ដល់ ៥០០ នាក់ កាន់ភ្លើងទៀនធំៗ ហែ[១] ។

ទី ៥ – ពួកកុមារីក្នុងព្រះបរមរាជវាំង ដែលជាមហាតឡិក កាន់គ្រឿងរាជូបភោគ សុទ្ធសឹងជាមាស-ប្រាក់ទាំងអស់ និងគ្រឿងប្រដាប់ផ្សេងៗ យ៉ាងដទៃទៀត ជាច្រើន ។

---

១ ទោះស្តេចចេញវេលាថ្ងៃ ក៏មានហែភ្លើងដែរ ។

ទី ៦ – ពួកស្រីក្នុងព្រះបរមរាជវាំង ជាក្រុមតម្រួតកាន់លំពែង នឹងខែលដើរហែជាជួរៗ ។

ទី ៧ – ក្បួនរថសេះ សិងរថនាដោយមាសព្រាលផ្លៅ ។

ទី ៨ – គណៈសេនាបតី នឹងព្រះរាជវង្សានុវង្ស ជាយ៉ាងច្រើន ជិះដំរី ដំរីជាសទៅដោយក្លស់ក្រហមព្រាល ។

ទី ៩ – ព្រះអគ្គមហេសី នឹងពួកព្រះស្រីស្នំ ខ្លះជិះអង្រឹងស្នែង ខ្លះ ជិះរថ ខ្លះជិះដំរី ច្រើនខ្នាន់ខ្នាប់ មានក្លស់មាសបើកបាំង ច្រើនជាងរយ ។

ទី ១០ – ព្រះមហាក្សត្រិយ៍ ស្តេចស្ថិតឈរលើដំរីព្រះទីនាំង ១ ព្រះហស្តទ្រង់កាន់ព្រះខាន់ យ៉ាងសង្ហា, ក្លុកដំរីព្រះទីនាំងសិងស្រោប មាសទាំងសងខាង មានព្រះក្លស់មាសជាង ២០ បើកបាំង នឹងមានទាហាន កងដំរី កងសេះ ហោមហែមជាយសបរិវារ ។

ការព្រះសាសនា – សាសនានៅប្រទេសកម្ពុជាក្នុងសម័យ នោះ មានតែសាសនាព្រាហ្មណ៍ នឹងព្រះពុទ្ធសាសនាប៉ុណ្ណោះ ។ តែសាសនាព្រាហ្មណ៍កំពុងរៀវរេចុះ ព្រះពុទ្ធសាសនាបានឡើងជា សាសនាសម្រាប់រដ្ឋ តាំងអំពីរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ មកហើយ ។ ជាវតាក្នុនថា អ្នកកាន់សាសនាក្នុងគ្រានោះមាន ៣ ពួក គឺ:

១ – ពួកបណ្ឌិត, ពួកនេះគេចាត់ជាបុគ្គលជាន់ខ្ពស់ ដោយមាន សេចក្តីចេះដឹងទាំងក្នុងផ្លូវសាសនាព្រាហ្មណ៍ ទាំងក្នុងផ្លូវព្រះពុទ្ធសាសនា

នឹងក្នុងច្បាប់ទម្លាប់ នឹងគតិលោកគ្រប់យ៉ាង ។ ពួកនេះ ស្លៀកពាក់ដូចអ្នកស្រុកធម្មតា ប៉ែកតែមានខ្សែអំបោះសបង់នៅកជាគ្រឿងសំគាល់ ។

២ — ពួកបស៊ី. ពាក្យថា បស៊ី ល្អៀងចេញពីពាក្យសំស្ក្រឹតថា តបស្វី (បាលីថា តបសី) ដែលយើងច្រើនហៅថាតាបស ។ ពួកនេះគឺជាអ្នកកាន់លទ្ធិសៃ មានប្រក្រតីគោរពរូបសិវលិង្គ ដែលគេច្រើនធ្វើអំពីថ្ម ទំនងប្រហែលអ្នកកាន់សាសនាតៅអិស្ទ ដែលគោរពដុំថ្មបែបនេះដែរ ។ ពួកនេះគេថា ស្លៀកពាក់សំពត់ពណ៌ក្រហមឬស ហើយមានសំពត់សស្រមាប់ជួតក្បាល មានអាស្រមតូចៗ ជាទីប្រតិស្ឋានសិវលិង្គ ហើយនឹងជាទីគោរពបូជា ក្នុងគ្រានោះ ។ ពួកនេះមានចំនួនតិចណាស់ទៅហើយ ទាំងគ្មានសេចក្ដីរុងរឿងទេ ។

៣ — ពួកចៅកូវ, នេះជាពាក្យខ្មែរបូរាណ សម្រាប់ហៅបព្វជិតក្នុងព្រះពុទ្ធសាសនា ត្រង់នឹងពាក្យក្នុងបច្ចុប្បន្នថា លោកសង្ឃ, សម័យនេះនៅមាននិយាយខ្លះដែររឿយៗ ដូចយ៉ាងលោកសង្ឃ លោកចៅកូវ ។ ព្រះពុទ្ធសាសនាក្នុងជំនាន់នេះ មានតែលទ្ធិស្ថវិរៈ ១ យ៉ាង, លទ្ធិមហា-យានរៀវពេយអស់ហើយ មកពីមិនសូវមានខ្លឹមសារ ។

ព្រះសង្ឃក្នុងសម័យនោះ ឃើញដូចជាមានការតែងតាំងឲ្យមានសមណសក្ដិធំ-តូចដូចក្នុងសម័យនេះដែរ ។ ប្រាកដក្នុងសេចក្ដីកត់ហេតុថា ព្រះសង្ឃអ្នកមានសមណសក្តិខ្ពស់ ទ្រង់ព្រះរាជានុញ្ញាតឲ្យប្រើរនឹង

ក្លស់ដងមាស, អ្នកមានសមណសក្តិបន្ទាប់មកឲ្យប្រើរ ទឹងក្លស់ដងប្រាក់, តាមជាន់នេះមកទៀត ឲ្យប្រើអ្វី មិនឃើញមានពោលដល់ ។

ព្រះបាទស្រីន្ទ្រវរ្ម័នទី ២ ទ្រង់កប់កាន់ព្រះពុទ្ធសាសនាលទ្ធិស្ថវីរៈ ។ ក្នុងសេចក្តីគត់ហេតុថា តែងស្តេចទៅនមស្ការព្រះចេតិយមាស ១ ជាញឹកញយ ។ ព្រះចេតិយមាសនោះប្រហែលជាទ្រង់សាងឡើងដោយព្រះអង្គឯង នៅក្នុងទីវត្តណាមួយដ៏មានក្នុងកំពែងក្រុង ។ បំណែកឯប្រជាជនខ្មែរភាគច្រើនជាបំផុត ជាអ្នកកាន់ព្រះពុទ្ធសាសនា មានវត្តអារាមដេរដាសនៅក្នុងព្រះរាជអាណាចក្រ ។

ព្រះបាទស្រីន្ទ្រវរ្ម័នទី ២ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិមកដល់ឆ្នាំ ព. ស. ១៨៥០ ទើបសោយទិវង្គត, គេថ្វាយព្រះនាមព្រះបរមសពដូចម្តេចមិនប្រាកដ ។ (មានត)

**សូមកុំភ្លេច**

អ្នកដែលទទួលរង់ទណ្ឌកម្ម ព្រោះជាតិមាតុភូមិ ជាមនុស្សប្រសើរ ។ សេចក្តីស្លាប់ ព្រោះយកអាសាមាតុភូមិ ទុកជាជោគដែលគួរប្រាថ្នា ។ សេចក្តីស្នេហាចំពោះមាតុភូមិ ប្រសើរខ្ពង់ខ្ពស់ជាងអ្វីទាំងអស់ ។

# រឿងអារ័ក្សថ្លែងរឿងខ្មែច្រាំ

## លោកសាង សាវ៉ាត លេខានុការ ក្រសួងហិរញ្ញវត្ថុ

*ប្រែពីភាសាបារាំងមកជាខ្មែរ*

(តមក)

---

## រឿងទី ៣

*អារ័ក្សមានវាចាថា "ឱ មហារាជ! មានទីក្រុងមួយ ហៅថា ក្រុងបាធ្វិន (Bardhvan) ។ ថ្ងៃមួយនោះព្រះបាទរូបសេន (Rûpsên) ជាព្រះចៅនៃទីក្រុងនេះ ស្ដេចទ្រង់ប្រថាប់ក្នុងបន្ទប់មួយ នៅក្បែរទ្វាររាជវាំង មានសូរស័ព្ទសន្ធឹកមួយ ចូលពីក្រៅមកដល់ព្រះអង្គ ។ ព្រះអង្គក៏ទ្រង់ត្រាស់សួរថា: "អ្នកណានៅមាត់ទ្វារ? រូបតើសូរស័ព្ទអ្វី?" ។*

*អ្នកយាមទ្វារទូលព្រះរាជាវិញថា "សំនួរដែលព្រះករុណាថ្លៃវិសេសត្រាស់សួរនេះប្រពៃណាស់! សូមព្រះករុណា ទ្រង់ជ្រាបថា ធម្មតាមាត់ទ្វាររបស់ជនអ្នកមានសម្បត្តិ ហើយដែលអ្នកផងគេស្គាល់ច្រើននាក់នោះ តែងសម្បូរណ៍ដោយជនទាំងឡាយដែលតណ្ហាក្នុងធនធានប្រយឹតប្រទាញពុំខាន; ឯជនទាំងឡាយនេះ អង្គុយហើយជជែកគ្នាអំពីរឿងផ្សេងៗ នេះហើយជាដើមហេតុនៃសូរស័ព្ទនេះ" ។ ព្រះរាជាលុះទ្រង់ព្រះសណ្ដាប់ដូច្នោះ ទ្រង់គង់នៅស្ងាត់ស្ងៀម ។*

កន្លែលនោះ មានអ្នកដំណើរម្នាក់មកពីទិសខាងត្បូង ជានាយសេនាកង់ទ័ព ឈ្មោះបីរបារ «Birbar» បានមកបង្ហាញខ្លួន នៅមាត់ទ្វារព្រះបរមរាជវាំង ដោយប្រាថ្នាចង់ចូលបំរើព្រះរាជា ។ ឯនាយយាមទ្វារលុះបានដឹងដំណឹងនេះ ក៏ទៅបង្គំទូលព្រះបេស្កាថា "សូមទ្រង់ព្រះមេត្តាប្រោស ! មានមនុស្សម្នាក់ ជាអ្នកចំបាំងបានមកដល់ ហើយមានបំណងចង់ថ្វាយខ្លួនបំរើព្រះអង្គ ឥឡូវឈរនៅមាត់ទ្វារ រង់ចាំព្រះរាជានុញ្ញាត ដើម្បីចូលបង្ហាញខ្លួនចំពោះព្រះអង្គ" ។ លុះកាលណាបានរាជានុញ្ញាតឲ្យនាំបុរសនោះមកហើយ នាយយាមទ្វារក៏ទៅនាំបុរសនោះមក ។ ព្រះមហាក្សត្រិយ៍មានព្រះរាជឱង្ការសួរថា: "អ្នកត្រូវការសុំអ្វីដើម្បីតាយរ៉ាយពល់ថ្ងៃ?" ។

បីរបារ ទូលថា: "សូមព្រះអង្គប្រោសព្រះប្រទានទូវមាស ១ ពាន់ហ៊ុន រាល់ថ្ងៃឲ្យទូលព្រះបង្គំ ព្រោះមាសចំនួនប៉ុណ្ណោះ ទូលព្រះបង្គំអាចចិញ្ចឹមជីវិតរស់បានហើយ" ។ ព្រះរាជាមានព្រះបន្ទូលសួរទៀតថា: "ចុះគ្រួសារអ្នកឯង មានប៉ុន្មានអ្នកដែលនៅជាមួយ?" ។ បីរបារ ក្រាបបង្គំទូលទៀតថា: "ដំបូងបង្អស់ ទូលព្រះបង្គំមានប្រពន្ធមួយ, បន្ទាប់ទី ២ កូនប្រុសមួយ, ទី ៣ កូនស្រីមួយ, ទី ៤ មានខ្លួនទូលព្រះបង្គំនេះ" ។

"ហេតុអ្វីបានជា មនុស្សនេះ សុំប្រាក់ច្រើនដល់ម្ល៉េះ?" ។ ប៉ុន្តែលុះទ្រង់គិតថា ប្រាក់អស់នេះ អាចមិនប្រយោជន៍ ដល់បុរសនេះ ។

កូនថៃមួយ ព្រះអង្គក៏ទ្រង់ត្រាស់ហៅអ្នកអមព្រះអង្គមក ទ្រង់បង្គាប់ឲ្យយកលុយឃុំរាល់ថ្ងៃ ចំនួន ១ ពាន់ហ៊ុន ដើម្បីឲ្យទៅបីរបារៗដែលបានមាស ១ ពាន់ហ៊ុននោះ កូនថ្ងៃនោះភ្លាម ក៏យកមាសនោះទៅដល់ផ្ទះ ។ បីរបារតាំងវែកជាពីរចំណែក មួយចំណែកឲ្យទៅព្រាហ្មណ៍, មួយចំណែកទៀត វែងចេញជាពីរភាគទៅទៀតហើយយកមួយភាគឲ្យទៅពួកបួជនីយេសក៍ (Pèlerins) ឲ្យទៅព្រះសង្ឃ ឲ្យទៅអ្នកដែលគោរពវិសុទ្ធ ឲ្យទៅសូមយាចក, ឯមួយភាគទៀតនោះឲ្យធ្វើម្ហូបអាហារឲ្យអ្នកក្រីក្របរិភោគ រួចអ្នកបរិភោគតែម្ហូបណាដែលសល់ ។

បីរបារធ្វើតែយ៉ាងដូច្នេះ ជាមួយប្រពន្ធ នឹងកូនរបស់ខ្លួន ។ រួចដល់ពេលយប់ បីរបារយកខែលនឹងដាវរបស់ខ្លួនមកកាន់ ហើយឈរយាមល្បាតនៅក្បែរក្រែព្រះរាជា ។ ដល់ព្រះអង្គតើនឡើងទ្រង់សួរថា: "អ្នកណានោះ?" ។ បីរបារទូលវិញថា: ទូលព្រះបង្គំឈ្មោះបីរបារទូលបង្គំចាំទទួលព្រះរាជត្រាស់" ។

គ្រប់តែពេលដែលព្រះរាជាទ្រង់ហៅ, បីរបារ បង្គំទូលតែពាក្យដដែលនេះ រួចតែងធ្វើតាមបង្គាប់ព្រះរាជាទាំងអស់ ទោះយ៉ាងណាក៏ដោយ ។ ដើម្បីឲ្យបានប្រាក់នោះ បីរបារមើលថែទាំព្រះមហាក្សត្រិយ៍តែយ៉ាងដូច្នោះ រៀងរាល់ទិវារាត្រី ។ បីរបារបរិភោគអាហារក្តី ផឹក

ទឹកក្តី ដេកក្តី សំពកក្តី ដើរក្តី ឬដើរលេងក្តី តែងគិតដល់កិច្ចការរបស់ចៅហ្វាយនាយខ្លួនណាស់ ។

នេះជាការណ៍ទូទៅ "ជនណាលក់អ្នកជិតខាងរបស់ខ្លួន ជននោះត្រូវគេលក់ខ្លួនវិញ" ។ ប៉ុន្តែអ្នកបំរើល្អដែលចូលធ្វើការ លក់ខ្លួនឯង ។ ដល់លក់ខ្លួនឯងដូច្នេះ ត្រូវតែនៅក្នុងឱវាទរបស់ចៅហ្វាយនាយរបស់ខ្លួន ។ ចុះតើអ្នកដែលនៅក្រោមឱវាទគេ អាចបានសប្បាយយ៉ាងណាទៅ? គឺជាការណ៍មួយពិតប្រាកដណាស់ ធម្មតាអ្នកដែលបំរើគេ ទោះមានជំរេះ ទោះប៉ិនប្រសប់ ទោះមានប្រាជ្ញា យ៉ាងណាក៏ដោយ ទៅជាគវិញមិនខានដោយសេចក្តីខ្លាច កាលណានៅពីមុខចៅហ្វាយនាយរបស់ខ្លួន ។ អ្នកបំរើនេះ តែងនៅស្ងៀមដកពប ហើយបានធូរស្បើយនោះ លុះត្រាតែបាននៅឆ្ងាយអំពីចៅហ្វាយនាយ ។ ដោយអាស្រ័យហេតុទាំងនេះហើយ បានជាអ្នកប្រាជ្ញនិយាយថា: "ការដែលធ្វើដោយសម្បជញ្ញៈ ពិបាកជាងការបួសទៅទៀត" ។

គេនិទានថា មួងនោះ នៅពេលយប់គេឮសូរសម្លេងស្រីម្នាក់យំនៅប៉ាធា ។ ព្រះមហាក្សត្រិយ៍ដែលទ្រង់បានឮសូរសម្លេងនេះ ស្តេចទ្រង់មានព្រះរាជឱង្ការថា: "អ្នកណានោះ?" ។ ឯបរិបារ ដល់ឮព្រះរាជាទ្រង់សួរ ក៏ឆ្លើយទូលទៅព្រះអង្គវិញថា: "ទូលព្រះបង្គំនៅនេះ តើព្រះអង្គបង្គាប់យ៉ាងណា?"

ព្រះអង្គក៏ទ្រង់បង្គាប់ថា: "ចូរឯងទៅត្រង់កន្លែងដែលគេព្យាត់ស្រីយំនោះ សាកសួរមើល តើវាយំអី? ហេតុយ៉ាងណា បានជាវាយំនេះ រួចត្រឡប់មកវិញឲ្យឆាប់" លុះទ្រង់បង្គាប់ដូច្នោះហើយ ព្រះរាជាទ្រង់គិតថា: "ដើម្បីពិសោធមើលចិត្តអ្នកបំរើរបស់ព្រះអង្គ គ្មានអ្វីក្រៅអំពីប្រើវា ពេលណាក៏ដោយដូច្នេះទេ ។ បើសិនណាជាវាធ្វើតាមបង្គាប់នេះ អញនឹងដឹងថាវាមានប្រយោជន៍ ។ បើវាប្រកែកវិញ វាគ្មានបានការអ្វីទេ ។ គឺក្នុងពេលលំបាកហើយ ដែលគេត្រូវពិសោធចិត្តបងប្អូន មិត្តភក្តិរបស់ខ្លួន ។ ១ ទៀត គឺនៅក្នុងគ្រាក្រីក្រហើយ ដែលគេស្គាល់ស្រី" ។

លុះទទួលបង្គាប់ហើយ បរិបារ ក៏ដើរឆ្ពោះតម្រង់ទៅកាន់ទីដែលសូរយំមកនោះ ឯព្រះរាជាដើម្បីជ្រាបចិត្តក្លាហានដល់ណា របស់បរិបារស្តេចទ្រង់ស្ទៀតពាក់ខ្មៅ ហើយយាងតាម ដោយមិនឲ្យដឹងឡើយ ។ កាលណាបុរសទៅដល់ប៉ាធា ដែលសម្លេងយំចេញមកនោះ អ្នកស្រឡាំងកាំងដោយបានឃើញស្ត្រីម្នាក់ល្អឯក ពាក់គ្រឿងអលង្ការពីក្បាលដល់ចុងជើង ។ នាងបួរ ហើយខាំធ្មេញ ដោយសេចក្តីអស់សង្ឃឹម ។ ជួនកាលនាងរាំ ជួនកាលនាងលោត ជួនកាលនាងរត់ទៅម្ខាង រួចទៅម្ខាងទៀត ប៉ុន្តែក្នុងភ្នែកនាងគ្មានទឹកភ្នែកសោះ ។ នាងញីញក់ក្បាលរបស់នាង នាងស្រែកទ្រហោមិនឈប់ នាងនទៀលលើដី ។ លុះ

ឃើញដូច្នោះ បរិបារ សាកសួរនាងអំពីហេតុដែលបណ្ដាលឲ្យនាងយំ នាងទុក្ខសោកយ៉ាងណាខ្លះហើយ តើមានទុក្ខអ្វី? ។ នាងឆ្លើយថា: "ខ្ញុំជាទេវតារក្សាស្ដេច" ។ បរិបារ សួរទៀតថា: "ហេតុអ្វីបាន ជានាងយំ?" ។

នាងក៏និទានថា កូនព្រះបរមរាជវាំងនឹងមានកើតអំពើអកុសល ដែលជាដើមហេតុនៃទុក្ខយ៉ាងធំ ។ នាងនិយាយបន្ថែមថា: "ខ្ញុំនឹងចាកចេញអំពីវាំងនេះហើយ ដល់មួយខែក្រោយទៀត ព្រះមហាក្សត្រិយ៍មុខជាទ្រង់ទិវង្គត ដល់ស្ដេចទ្រង់ប្រឈួនយ៉ាងធ្ងន់ធ្ងរ ។ ខ្ញុំអាសូរដល់ហេតុអាក្រក់នេះណាស់ ដែលធ្វើឲ្យខ្ញុំមានទុក្ខព្រួយជាពន់ពេក ព្រោះខ្ញុំតែងរក្សាសេចក្ដីសុខក្នុងវាំងនេះ ។ ឯទុក្ខនេះជៀសមិនផុតទេ" ។

បរិបារសួរថា: "តើគ្មានថ្នាំណាមួយ អាចទប់ទល់បានឬអ្វី? តើគ្មានអ្វីមួយអាចជួយស្រង់ជីវិតព្រះរាជា ហើយធ្វើឲ្យព្រះអង្គគង់ធម្មាបាន ១០០ ព្រះវស្សាទេឬអ្វី?" ។ នាងឆ្លើយទៀតថា: "ចំនួន ៤ យោជន៍ពីនេះ មានព្រះវិហារមួយរបស់ទេវតាមួយ ។ បើសិនណា អ្នកកាត់សិរសាកូនប្រុសរបស់អ្នក ដោយដៃអ្នក យកទៅថ្វាយដល់ទេវតានោះ ព្រះមហាក្សត្រិយ៍ នឹងបានសោយរាជ្យចំនួន ១០០ ឆ្នាំទៅមុខទៀត ហើយគ្មានទុក្ខសោកអ្វីអាចមានដល់ព្រះអង្គឡើយ" ។

លុះកាលណាបានឮពាក្យអស់នេះហើយ បរិវារត្រឡប់ទៅលំនៅអាត្មាវិញ ដោយមានព្រះមហាក្សត្រិយ៍លបតាមពីក្រោយផង ៗ លុះបានទៅដល់ផ្ទះរបស់អ្នកកាលណា អ្នកដាស់ភរិយា ហើយនិទានរឿងសព្វគ្រប់ប្រាប់នាង ៗ ឯនាង លុះបានឮដូច្នោះ ក៏ដាស់កូនប្រុសនឹងកូនស្រីរបស់នាង ៗ នាងមានវាចាទៅកាន់កុមារថាដូច្នេះ "កូនប្រុសមាសម្ដាយ កាលណាឯងថ្វាយសិរសាឯង ព្រះមហាក្សត្រិយ៍នឹងរួចជន្មជីវិត ហើយព្រះអង្គបានសោយសម្បត្តិតទៅមុខទៀត" ៗ

លុះបានឮពាក្យនេះ កុមារឆ្លើយតបប្រាប់មាតាថា: "ឱអ្នកម្ដាយ! វត្ថុដ៏ថ្លៃថ្លាបំផុតរបស់កូននេះ គឺបង្គាប់របស់អ្នកម្ដាយ រួចគឺប្រយោជន៍របស់នាយចៅហ្វាយកូន ៗ ម្យ៉ាងទៀត ក្នុងលោកិយនេះ តើមានវត្ថុណាមួយដែលគាប់ប្រសើរជាងធ្វើពលិកម្មរូបខ្លួន ថ្វាយដល់ទេវតានោះ? បើសិនណាពលិកម្មនេះ ខានមិនបានទេ មិនត្រូវរារែកឡើយ ៗ មានភាសិតមួយនិយាយថា: "ជនណាមានវត្ថុទាំងប្រាំដូចតទៅនេះ គឺកូនមួយដែលចំណុះ, រូបកាយមួយដែលគ្មានរោគា, វិទ្យាសាស្ត្រ, មិត្តមួយមានប្រាជ្ញា នឹងប្រពន្ធមួយដែលស្ដាប់បង្គាប់ ជននោះអាចបានសប្បាយជាពន់ពេក ហើយគ្មានទុក្ខអ្វីឡើយ ៗ ចំណែកអ្នកបំរើម្នាក់ចិត្តក្បត់, ស្ដេចមួយអន្ដកំណាញ់, មិត្តមួយអាក្រក់, ប្រពន្ធមួយឯកច្ឆន្ទ វត្ថុ

ទាំងបួននេះដែលនាំឲ្យមានទុក្ខ ហើយនាំឲ្យវិលវល់ជាពន់ពេក" ។ ឯបីបារ និយាយទៅកាន់ភរិយារបស់អ្នកថា "បើសិនណាអូនសុខចិត្ត ឲ្យកូនមកបងដោយរីករាយ បងនឹងយកកូននេះទៅ រួចបងនឹងសម្លាប់ថ្វាយទេវតាដោយស្នេហាស្មោះក្រៃណាស់នេះ" ។

នាងក៏និយាយថាដូច្នេះ "កូនប្រុស កូនស្រី មិត្តភក្តិ បងប្អូនរបស់ខ្ញុំគ្មានជាអ្វីទាំងអស់ ។ សេចក្តីរីករាយសប្បាយរបស់អូន គឺស្ថិតនៅនឹងរូបបង ។ គេមានសរសេរក្នុងសៀវភៅទសករិយាថា "ស្រីមួយមិនអាចល្អទៅកើត ដោយនាងនោះធ្វើបុណ្យ ឬបួសនោះទេ គឺដោយនាងនោះបំរើប្តីយ៉ាងស្មោះត្រង់ ទោះប្តីនោះ គ ថ្លង់ ខ្វាក់ ខ្វាក់ម្ខាង ឃ្លង់ ឬគមខ្លួនយ៉ាងណាក៏ដោយ ។ បើស្រីនោះមិនស្តាប់បង្គាប់ប្តីទេ មុខជាធ្លាក់ក្នុងអវិចី ទោះបីនាងនោះបានធ្វើគុណធម៌យ៉ាងណាក្នុងលោកនេះក៏ដោយ" ។

កុមារនិយាយម្តងវិញថា: "លោកឪពុក! មនុស្សដែលមានប្រយោជន៍ដល់ចៅហ្វាយនាយរបស់ខ្លួន តែងមានជីវិតមួយបរិបូណ៌ដោយទ្រព្យនៅស្ថានកណ្តាលនេះ រួចដោយសារដម្លៃរបស់សង្ខារនេះ មនុស្សនោះអាចបានសុខក្នុងលោកទាំងពីរមិនខាន" ។

នាងបុត្រិនិយាយថា: "បើសិនមាតាបំពុលបុត្រ, រួចបិតាលក់បុត្រ ឯស្ដេចរឹបជាន់សម្បត្តិ តើអ្នកណាមួយការពារយើង?" ។

លុះជជែកដូច្នេះហើយ ជនទាំងបួននាក់ នាំគ្នាត្រសងទៅព្រះវិហារ ឯព្រះមហាក្សត្រិយ៍ក៏ទ្រង់យាងលបតាមពីក្រោយដែរ ។

កាលណាបីរបារទៅដល់ហើយ អ្នកចូលទៅក្នុងព្រះវិហារទេវតា សំពះរួចបន់ថា: "ឱទេវី! ខ្ញុំធ្វើពលិកម្ម កូនប្រុសខ្ញុំថ្វាយលោក សូមឲ្យលោកធ្វើតបវិញ ដោយធ្វើឲ្យសក្ការស្ដេច កើនឡើងឲ្យបាន ចំនួន ១០០ ឆ្នាំទៀត" លុះបន់ដូច្នោះរួចអ្នកហូតដាវ ។ ឯសិរសាបុត្រា របស់អ្នក ក៏ដាច់ធ្លាក់ដល់ធរណី ។ លុះឃើញបងប្រុសនាងស្លាប់ដូច្នោះ នារីកូនស្រីក៏យកដាវកាត់កខ្លួនឯង ហើយក្បាលនាងក៏ធ្លាក់ដាច់អំពីខ្លួននាងទៅ ។ ឯភរិយារបស់បីរបារ លុះឃើញកូនប្រុស កូនស្រីស្លាប់អស់ដូច្នោះ នាងចាក់បំពង់កនាងមួយកាំបិត រួចក្បាលនាងក៏ធ្លាក់ដែរ ។ លុះឃើញស្លាប់ទាំងបីដូច្នោះហើយ បីរបារគិតថា: "ឥឡូវនេះ កូនរបស់អញស្លាប់អស់ហើយ តើនៅបំរើអ្វី? តើអញឲ្យមាសដែលអញបានអំពីស្ដេច ទៅអ្នកណា?" ថាហើយអ្នកយកកាំបិតស្នៀតចាក់ខ្លួនឯង រួចសិរសារបស់អ្នកក៏ដាច់ធ្លាក់ដល់ដី ។

លុះឃើញជនទាំងបួនស្លាប់ ព្រះរាជាទ្រង់គិតថា: "ក្រុមញាតិរបស់បីរបារទាំងមូលស្លាប់ពីព្រោះអញ ។ សុំឲ្យអន្តរធានដល់រដ្ឋកិច្ចបាល

ដែលបានបំផ្លាញត្រកូលមួយទាំងមូល រួចដែលបុគ្គលម្នាក់កាន់រាជ្យភិបាលនេះ មិនត្រូវសោយរាជ្យដូច្នេះទេ" ។ លុះទ្រង់គិតដូច្នេះ ស្ដេចទ្រង់ទាញដាវរបស់ព្រះអង្គ ដើម្បីពិឃាដជីវិតព្រះអង្គ ស្រាប់តែទេវតាមកដល់ចាប់ព្រះហស្ដ ហើយនិយាយទូលទៅព្រះអង្គថា: "នែកូន! យើងពេញចិត្តនឹងបំណងរបស់អ្នកហើយ រួចយើងឲ្យអ្នកសុំអ្វី យើងសុំឲ្យបានតាមចិត្ត" ។

ព្រះមហាក្សត្រិយ៍ទ្រង់ឆ្លើយវិញថា: "មាសម្ចាស់! បើអ្នកសប្បាយនឹងកូនហើយ កូនសុំឲ្យអ្នកធ្វើឲ្យសត្វទាំងប្អូននេះរស់មានជីវិតឡើងវិញ" ។ ទេវតានិយាយថា "មិនអីទេ យើងធ្វើឲ្យ" ។

អាក្រក់លុះនិទានរឿងមកដល់នេះទើបបន្ថែមថា: "សាធុ អ្នកបំរើណាដែលមានចិត្តស្នេហានាយចៅហ្វាយរបស់ខ្លួន មិនគិតរួញរាបូជាជីវិតនឹងជីវិតគ្រួសាររបស់ខ្លួន,ម្យ៉ាងទៀត សាធុ ស្ដេចអង្គណា ដែលមិនស្ទាក់ស្ទើរចង់ជាប់នឹងព្រះរាជធានី ហើយនឹងសម្ភាររបស់ព្រះអង្គ" ។

"នែមហារាជ ខ្ញុំសូមសួរទ្រង់ ក្នុងបណ្ដាជនទាំងប្រាំនេះ តើជនណាមួយមានគុណធម៌លើសគេបំផុត?" ។

ព្រះបាទពិក្រមាទ្រង់ឆ្លើយថា: "គឺស្ដេច" ។

អាក្រក់សួរទៀតថា "តើហេតុដូចម្ដេច?" ។

ព្រះបាទពិករ័ន មានព្រះរាជឱង្ការថា: "ការដែលអ្នកបំរើ បូជាជីវិតដល់នាយចៅហ្វាយ ជាការធម្មតាទេ ព្រោះជាករណីកិច្ចរបស់ខ្លួន; ប៉ុន្តែស្តេចចាកចោលរាជធានីដោយស្រឡាញ់នាយអាមាត្យរបស់ព្រះអង្គ ស្តេចអង្គនេះ គ្មានទន់គិតដល់ជីវិតរបស់ព្រះអង្គ ដែលព្រះអង្គទុកដូចចំបើងមួយចំរៀក គុណធម៌របស់ព្រះអង្គ មានលើសគុណធម៌របស់បរិវារ" ។

អារ័ក្សលុះឮព្រះរាជឱង្ការដូច្នោះ ត្រឡប់ទៅប៉ាឆាវិញ ហើយព្យួរខ្លួនលើព្រឹក្សាដូចមុន ។ ឯព្រះមហាក្សត្រិយ៍ ដល់ត្រឡប់ទៅកន្លែងនោះ ស្តេចចាប់អារ័ក្សដាក់លើស្មា ហើយលើយានទៅ ។

មនុស្សមានជំនឿ ទឹកដីក៏មានជំនឿ, ធម៌សាមគ្គីនាំឲ្យមនុស្សក្នុងសង្គមមានជំនឿ, ដូច្នេះត្រូវយើងខ្មែរខំបណ្ដុះធម៌សាមគ្គីទើបនឹងមានសង្ឃឹម

(មានត)

# ពិធីប្រឡងធម្មវិន័យ

### នៅវត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប

## ព្រះមហាឧត្តមវិជ្ជា កែ-អឿន (វីរិយប្បញ្ញោ)

រៀបរៀង

---

កាលពីថ្ងៃសៅរ៍ ២ កើតខែមិគសិរ ឆ្នាំថោះត្រីស័ក ព.ស. ២៤៩៤ (១៥-១២-៥១) នៅវត្តព្រះព្រហ្មរតន៍ សៀមរាប មានពិធីបុណ្យមួយដ៏ឧឡារិក គឺបុណ្យប្រឡងធម្មវិន័យចំពោះសិស្ស ១៥៤ ដែលបានសិក្សាក្នុងសាលាធម្មវិន័យ វត្តព្រះព្រហ្មរតន៍ ឆ្នាំ ១៩៥១ នេះ ដោយកាលបរិច្ឆេទប្រឡងនេះមកដល់ស្រាប់ ៗ ក្នុងពេលនោះ លោកវរសេនីយត្រី ឈួនមូលពេជ្រ និងពុទ្ធបរិស័ទចំណុះវត្ត បានប្រារព្ធធ្វើបុណ្យឆ្លងសាលាធម្មវិន័យ ដែលបានជួសជុលជាថ្មី ឲ្យសមរម្យជាសាលាសម្រាប់សិក្សាក្នុងព្រះពុទ្ធសាសនា ដើម្បីឧបត្ថម្ភដល់សិស្សក្នុងពេលប្រឡងនោះផង ៗ

ថ្ងៃទី ១— ពិធីបុណ្យនេះបានប្រារព្ធធ្វើតាំងពីល្ងាចថ្ងៃ ១៤ ខែធ្នូ ដោយរៀបចំរើនព្រះបរិត្ត មានព្រះសង្ឃនិងឥស្សរជន ព្រមទាំងពុទ្ធបរិស័ទនិមន្ត និង អញ្ជើញទៅកាន់ពិធីបុណ្យនោះជាច្រើនរយនាក់ ៗ កាលព្រះសង្ឃនិងឥស្សរជនពួកពុទ្ធបរិស័ទនិមន្ត និង អញ្ជើញទៅជួបជុំហើយ, ម៉ោង ៨ យប់ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត ៗ ចប់ និមន្តព្រះសមុហ៍គណ សុ-ជិត វត្តគ បាត់ដំបង សំដែងធម៌ទេសនា ៗ

ប្រៀទី ២ — ព្រឹកឡើងថ្ងៃ ២ កើតខែមិគសិរ (១៥-១២-៥១) ម៉ោង ៨, ការជួបជុំសិស្សទាំង ២ ថ្នាក់ គឺថ្នាក់ត្រី ១២៤ រូប ថ្នាក់ទោ ២៨ រូប, ការហៅឈ្មោះឲ្យចូលទៅអង្គុយតាមកន្លែងតុនិងបែកក្រដាសសម្រាប់ប្រឡង, សិស្សអង្គុយរៀបរយតាមកន្លែងរួចហើយ, ពេលនោះពួកក្រុមមេប្រយោគ មានព្រះសុមង្គលសីលាចារ្យមេគណជាអធិបតី ព្រះគ្រូបញ្ញាវិជ្ជាអនុគណជាអធិបតីរង និងលោកចៅហ្វាយស្រុកៗ សៀមរាប លោកកូឈួយខែត្រអញ្ជើញទៅជាកិត្តិយសមេប្រយោគផង ។ បើកវិញ្ញាសាទី ១ គឺ សាសនសុភាសិតទាំងថ្នាក់ត្រី ថ្នាក់ទោ ដែលនៅក្នុងស្រោមបិទកាកល័ខ ហើយសរសេរនៅក្តារធំ ឲ្យសិស្សតែងជារបៀបទេសនា ។ ម៉ោង ១២ ពុទ្ធបរិស័ទប្រគេនបង្ហាន់ដល់សិស្សប្រឡង ។ ម៉ោង ៣ រសៀល គោះគាំងប្រជុំសិស្សដូចមុន អធិបតីបើកវិញ្ញាសាទី ២ គឺ: ប្រស្នាធម្មវិភាគចំនួន ៧ ខ ទាំងថ្នាក់ត្រី ថ្នាក់ទោ ឲ្យសិស្សសរសេរឆ្លើយ ។ លុះដល់ម៉ោង ៨ យប់ និមន្តព្រះអាចារ្យ ខៀវ-ជុំ វត្តលង្កា ភ្នំពេញសំដែងធម៌ទេសនាៗ ចប់ ចាប់លេងល្ខោនជាតិតទៅ ដរាបដល់ម៉ោង ១២ កន្លះយប់ ។

ប្រៀទី ៣ — ថ្ងៃ ៣ កើតខែមិគសិរ (១៦-១២-៥១) ម៉ោង ៣ រសៀល ជួបជុំសិស្សដូចមុន អធិបតីបើកវិញ្ញាសាទី ៣ គឺ ប្រស្នាពុទ្ធប្បវត្តិ និងប្រស្នាអនុពុទ្ធប្បវត្តិទាំងថ្នាក់ត្រីថ្នាក់ទោចំនួន ៧ ខ ឲ្យ

សិស្សសរសេរឆ្លើយ. ម៉ោង ៨ យប់ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត ៧ រូប ហើយ ព្រះមហាឧត្តមរិដ្ឋា កែ-អឿន ថ្លែងសុន្ទរកថា ដូចមានសេចក្តីតទៅនេះ :–

សូមថ្វាយបង្គំព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណ !
សូមថ្វាយបង្គំព្រះតេជព្រះគុណព្រះគ្រូបញ្ញាវិជ្ជាអនុគណ !
សូមពិតថេរវាចា ព្រះថេរានុត្ថេរទាំងឡាយ !
សូមចំរើនពរព្រះតេជព្រះគុណវរសេនីយត្រី !

សូមចំរើនពរលោកនាយកក្រុមព្រះនគរបាល - នឹងឥស្សរជនទាំង-ឡាយ ព្រមទាំងលោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ! ខ្ញុំព្រះករុណាអាត្មាភាពជាតំណាងនាមព្រះសង្ឃជាសិស្សានុសិស្សជាដើម សូមអភ័យទោស ប្រកាសជាឧឡារិកចំពោះព្រះតេជព្រះគុណ, លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយថា ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស ព្រោះមានពិធីបុណ្យប្រឡងធម្មវិន័យនៃសិស្សដែលបានសិក្សា ក្នុងឆ្នាំ ១៩៥១ នេះ នឹងពិធីបុណ្យឆ្លងសាលាធម្មវិន័យនេះ ។ ក្នុងឱកាសបុណ្យនេះ ព្រះតេជព្រះគុណ, លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយបានអញ្ជើញមកជាអធិបតីនឹងអនុមោទនាការកុសល ទុកជាកិត្តិយសដ៏ប្រសើរបំផុត ចំពោះការសិក្សាដែលខំព្យាយាមបំពេញករណីយកិច្ចតាមវគ្គបំណង ដែលប៉ងរួចមកហើយ; វគ្គបំណងនេះ បើពិចារណាតាមអត្ថព្យញ្ជនៈ បានសេចក្តី

វែងឆ្ងាយទូលាយ ពោលគឺទំនុកបំរុងព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿង, ការសិក្សាព្រះពុទ្ធសាសនាដែលបានរុងរឿងទាំងនេះក៏ដោយសារតែព្រះតេជព្រះគុណជាឥស្សរជន និងពុទ្ធបរិស័ទទាំងឡាយមានសាមគ្គីធម៌ ព្រមព្រៀងមូលមិត្តគ្នាជាឯកច្ឆន្ទ ជួយឧបត្ថម្ភការតាមកម្លាំងទ្រព្យ កម្លាំងសតិប្បញ្ញាគ្រប់ៗគ្នា ។ ការជួយឧបត្ថម្ភសាលាធម្មវិន័យនេះ ឈ្មោះថាជួយឧបត្ថម្ភដល់ព្រះពុទ្ធសាសនាឲ្យបានចំរើនរុងរឿងផង ឈ្មោះថាអប់រំព្រះសង្ឃដែលនៅក្នុងមុឡ្ហភាព ឲ្យឡើងទៅកាន់បណ្ឌិតភាពផង ឈ្មោះថារបនានាំខ្លួនឲ្យមានវិជ្ជា ឲ្យមានពន្លឺភ្លឺស្វាង ដើម្បីឲ្យភាសានិងអក្សរជាតិវិវត្តន៍ទៅកាន់វឌ្ឍនធម៌បានផង ។

ម្យ៉ាងទៀតអាចនិងពោលបានថា លោកជាឥស្សរជនដែលជួយឧបត្ថម្ភការសិក្សាទុកដូចជាវត្ថុធាតុដែលមានដីជាតិល្អ, សាលាធម្មវិន័យទុកជាដើមវុក្ខា, ព្រះសង្ឃដែលបានសិក្សាទុកដូចជាបុប្ផា ដែលមានក្លិនក្រអូប, ឧបាសក ឧបាសិកា ទុកដូចជាឃ្មុំឬកន្ទង់ តែងជញ្ជក់នូវលំអងបុប្ផាទាំងនោះ មកធ្វើជាសំបុក គឺចំណេះវិជ្ជាគ្រប់ៗគ្នា ។ សាលាធម្មវិន័យជាខួរសិរសីនៃព្រះពុទ្ធសាសនា, ហើយជាវិជ្ជាស្ថានមួយដ៏ប្រសើរអាចបណ្តុះពូជព្រះសង្ឃដែលបានសិក្សា ឲ្យចេះដឹងទៅជាបណ្ឌិតអ្នកប្រាជ្ញអាចប្រតិបត្តិធម៌វិន័យ ឲ្យដើរទៅតាមផ្លូវត្រង់ ។

ថ្ងៃនេះទុកជាថ្ងៃជយមង្គល នាំឲ្យសិស្សដែលបានមកប្រឡងនឹករលឹកទុកជាអនុស្សាវរីយ៍ក្នុងមនោវិញ្ញាណ ដែលបញ្ចេញនូវសុភនិមិត្តអាចទស្សនាទៅហើយនាំឲ្យកើតបីតិបាមោជ្ជៈ ប្រកបដោយអច្ឆរិយភាព, ភ្លេចទឹកដល់ការព្រួយលំបាកនឿយហត់អំពីអតីតកាល ថែមទាំងឲ្យសិស្សដែលប្រឡងចូល ធ្វើមនសិការទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃថានឹងព្យាយាមឲ្យពេញកម្លាំងដើម្បីនឹងសម្រេចឥដ្ឋផលនេះ ។

អាត្មាភាព សូមថ្លែងកតញ្ញូកតវេទីចំពោះព្រះតេជព្រះគុណ, លោក-អ្នកទាំងឡាយ, ដែលបានអញ្ជើញមកជួយឧបត្ថម្ភដោយសោមនស្សដ៏ឧត្តម កិច្ចដែលព្រះតេជព្រះគុណលោកអ្នកទាំងឡាយបានធ្វើហើយនេះជាកិច្ចមានសារៈប្រយោជន៍ចំពោះសិស្សដែលបានសិក្សាមកហើយ បុំរុងនឹងសិក្សាតទៅទៀត ។ ព្រះតេជព្រះគុណលោកអ្នកទាំងឡាយដែលមានសាមគ្គីធម៌មកជួយឧបត្ថម្ភការកុសលនេះ ឲ្យបានសម្រេចដោយយល់ថា សាលាធម្មវិន័យជាឃ្លាំងធម៌មួយធំ សម្រាប់ដំកល់ទុកនូវវិជ្ជាខាងពុទ្ធសាសនានឹងអក្សរសាស្ត្រខ្មែរ ។

ក្នុងអវសាននេះ សូមឧទ្ទិសជូនកុសលដែលកើតដោយបុណ្យនេះចំពោះព្រះតេជព្រះគុណ, លោកអ្នកជាពុទ្ធមាមកជនទាំងឡាយ ហើយសូមគុណានុភាពព្រះត្រៃរ័ត្ន ព្រមទាំងវត្ថុសក្តិសិទ្ធិក្នុងសកលលោក នឹងផលានិសង្សនៃបុណ្យនេះ ប្រសិទ្ធិពរជូនព្រះតេជព្រះគុណ លោក

អ្នកជាពុទ្ធមាមកជនទាំងឡាយ ឲ្យបានប្រកបដោយសេចក្ដីសុខសេចក្ដីចំរើន សិរីសួស្ដីជយមង្គលគ្រប់ជំពូក នឹងបានសម្រេចនូវត្រៃពិធសម្បត្តិជាឥដ្ឋមនុញ្ញផលគឺ សម្បត្តិមនុស្ស ១ សម្បត្តិសួគ៌ ១ សម្បត្តិព្រះនិព្វាន ១ កុំបីឃ្លៀងឃ្លាតឡើយ ! ។

លុះចប់សុន្ទរកថា គេនិមន្ដព្រះមហាឧត្ដមវិជ្ជាកៃ-អៀន នឹងព្រះអាចារ្យសុខ-សាន វត្ដព្រះព្រហ្មរតន៍ សំដែងធម៌ទេសនាបុច្ឆា-វិសជ្ជនាទេសនាចប់ លេងល្ខោនជាតិតទៅដូចយប់មុន ។

ថ្ងៃទី៤— ថ្ងៃ ៤ កើតខែជង្ឍ (១៧-១២-៥១) ម៉ោង ១១ ព្រឹក ពុទ្ធបរិស័ទពប់បាត្រថ្វាយសាលាធម្មវិន័យ;

ម៉ោង ៣ រសៀល អធិបតីបើកវិញ្ញាសាទី ៤ គឺ: ប្រស្នាវិន័យទាំងថ្នាក់ត្រីថ្នាក់ទោចំនួន ៧ ខ ឲ្យសិស្សសរសេរឆ្លើយ;

ម៉ោង ៨ យប់ និមន្តវិន័យធរអនុគណ ឯក-ញឹម វត្តធម្មិស្សរការាម (រលួស) សំដែងធម៌ទេសនា។ចប់ ចាប់លេងល្ខោនជាតិតទៅ ដរាបដល់ម៉ោង ១ ទើបឈប់ ។

ប្រឡងធម្មវិន័យក្នុងពេលនេះ ក្រសួងធម្មការបានចាត់តាំងព្រះសុមង្គលសីលាចារ្យមេគណទិត-ទិម វត្ដដំណាក់ សៀមរាប ជាអធិបតី, ព្រះសុមង្គលសីលាចារ្យបានតាំងគណ:កម្មការសមាជិក ៨ រូបទៀត ទាំងថ្នាក់ត្រីថ្នាក់ទោ ដើម្បីត្រួតត្រាការប្រឡងតាមបន្ទប់ប្រឡង ។

ថ្នាក់ត្រីមានសមាជិក ៤ រូប គឺ:

១ – ព្រះវិន័យធរអនុគណ ឯក ញឹម
២ – ព្រះសមុហ៍គណ សូ-ងិត
៣ – ព្រះមហាឧត្តមវិជ្ជា កែ-អឿន
៤ – ព្រះអាចារ្យ ស៊ុន-សារិន

} ជាសមាជិក

ចំណែកថ្នាក់ទោ មានសមាជិក ៤ រូប គឺ:

១ – ព្រះគ្រូបញ្ញាវិជ្ជាអនុគណ អ៊ុក-ម៉ៅញ ជាអធិបតីរង
២ – ព្រះមហាបរិយត្តិ ម៉ាស-លន
៣ – ព្រះអាចារ្យ សុខ-សាន
៤ – ព្រះមហាបរិយត្តិ ព្រំ-យឹម

} ជាសមាជិក

ព្រះមហាបរិយត្តិ ម៉ាន់-ឡាយ ជាលេខាធិការ ។

កាលបើសិស្សធ្វើវិញ្ញាសានីមួយៗ ចប់ហើយ ក្រុមសមាជិកបានយកវិញ្ញាសានោះ ចែកទៅក្នុងស្រោមសំបុត្រធំមួយ ហើយបិទកាកល័ខប្រថាប់ត្រាពីខាងក្រៅជូនទៅអធិបតីៗ នឹងចាត់បញ្ជូនទៅព្រះតេជព្រះគុណព្រះមុនីកោសលមេគណវត្តពោធិ៍វាលខេត្តបាត់ដំបង តាមសេចក្តីបង្គាប់អំពីក្រសួងធម្មការ, ព្រះតេជព្រះគុណព្រះមុនីកោសល នឹងចាត់ឲ្យទៅគណកម្មការត្រួតសំណុំរឿងប្រឡងនោះ ។

ក្នុងរវាងបុណ្យប្រឡងធម្មវិន័យប៉ុន្មានថ្ងៃនេះ លោកវរសេនីយត្រី ឈួនម្ជុលពេជ្រ បានចំណាយហិរញ្ញវត្ថុជាបៀវត្សចំនួន ២០០០៛,០០ ជួយឧបត្ថម្ភក្នុងពិធីបុណ្យប្រឡង ព្រមទាំងលោកអ្នករាជការក្នុងខែត្រ ក្រសួងខ្លះបានជួយឧបត្ថម្ភជាមួយផង ព្រមទាំងពុទ្ធបរិស័ទជិតឆ្ងាយបាន ជួយឧបត្ថម្ភក្នុងបុណ្យប្រឡងនេះ ដរាបដល់រួចកិច្ចប្រឡង ។

ឱ! ខេមរជាតិ

សេចក្តីល្អអាក្រក់ក្នុងកិច្ចការអ្វីគ្រប់យ៉ាង មិនមែនទេវបុត្រ ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មណា ធ្វើឲ្យយើងទេ មានតែខ្លួនយើង ហ្នឹងហើយ ធ្វើឲ្យខ្លួនយើង ។

វរសេនីយត្រី ឈួនម្ជុលពេជ្រ